# ចំណាប់អារម្មណ៍អំពីប្រធានបទ "ការកាត់ក្ដី"

ជាតុមួយក្នុងចំណោមកេរដំណែលវប្បធម៌ខ្មែរ ដែលដូនតាបានបន្សល់ទុករហូតមកដល់បច្ចុប្បន្ននិងប្រជាជននិយមចូលចិត្តនិទានបន្តពីមនុស្សម្នាក់ទៅមនុស្សម្នាក់ ពីជំនាន់មួយទៅជំនាន់មួយគឺ *រឿងព្រេងខ្មែរ* ។ ចាស់ៗគឺជាជនសំខាន់ជាងគេក្នុងការធ្វើឲ្យរឿងព្រេងខ្មែររស់រានមានជីវិតនិងមានប្រជាប្រិយភាព។ សព្វថ្ងៃនេះដោយសារប្រព័ន្ធផ្សព្វផ្សាយដូចជាវិទ្យុ ទូរទស្សន៍ កុនជាដើមមានឥទ្ធិពលខ្លាំងលើមនុស្ស ការបន្តនិទានរឿងព្រេងដែលជាប្រពៃណីរបស់ប្រជាជនហាក់បីដូចជាមិនសូវមានប្រជាប្រិយភាពទេ។ យើងបារម្ភថារឿងព្រេងដែលបង្កប់នៅក្នុងខួរក្បាលរបស់ចាស់ៗអាចនឹងបាត់បង់ទៅជារៀងរហូតជាមួយនឹងជរាភាព និងមរណភាពរបស់ពួកគាត់។ យើងយល់ថាមានវិធីសាស្ត្រមួយសំខាន់ដែលធ្វើឲ្យរឿងព្រេងអាចបន្តជីវិតនិងតួនាទីរបស់ខ្លួនតទៅទៀតបាននោះគឺ ការប្រមូលចងក្រងកត់ត្រាទុកនិងធ្វើការបោះផ្សព្វផ្សាយនូវរឿងទាំងនោះឡើងវិញ ទើបអ្នកជំនាន់ក្រោយអាចស្គាល់និងក្រេបរស់ជាតិបាន។

ទស្សនាវដ្ដីដែលលេចចេញជារូបរាងនាពេលនេះសុទ្ធតែកើតចេញពីកម្មវត្ថុខាងលើ។ វាជាផ្នែកមួយនៃគម្រោងស្រាវជ្រាវស្ដីពី *ប្រជុំរឿងព្រេងខ្មែរថ្មី* របស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យក្រោមកិច្ចឧបត្ថម្ភពីមូលនិធិស្ថានទូតអាមេរិកប្រចាំនៅកម្ពុជា។ គម្រោងនេះមានគោលបំណងសង្គ្រោះរឿងព្រេងដែលកប់នៅក្នុងការចងចាំរបស់ចាស់ៗដែលរស់នៅតាមជនបទនានា ឲ្យរស់រានមានជីវិតឡើងវិញក្នុងន័យថែរក្សាវប្បធម៌ខ្មែរ និងធ្វើការស្វែងយល់ផងដែរថាតើរឿងព្រេងទាំងឡាយ ដែលប្រជាជននៅចេះចាំនោះ មានការលក្ខណៈប្រែប្រួល

យ៉ាងណាខ្លះ។ ជាមួយគ្នានេះក៏មានការប្រមូលរឿងព្រេងថ្មីៗដែលមិនធ្លាប់បានប្រមូលពីមុនមកតាមលទ្ធភាពដែលអាចធ្វើបានដើម្បីយកមកចងក្រងបន្តទៀត។

ជាការពិតណាស់ រឿងព្រេងខ្មែរមានបង្កប់នូវខ្លឹមសារសំខាន់ៗជាច្រើនដូចជា រឿងទាក់ទងនឹងប្រពៃណីទំនៀមទម្លាប់ ដើមកំណើត ទីតាំងភូមិសាស្ត្រ ស្ត្រី ល្បិចកិច្ចកល ខ្មោច និងការកាត់ក្ដី ដែលវាសុទ្ធតែផ្ដល់ជាចំណេះដឹងនិងគតិអប់រំល្អៗ ហើយយើងយល់ថាវាអាចជាគំរូសម្រាប់តម្រង់ផ្លូវមនុស្សខ្មែរគ្រប់ពេលវេលា។

អត្ថន័យក្នុងទស្សនាវដ្ដីនេះផ្ដោតសំខាន់ទៅលើការកាត់ក្ដី។ អ្នកអាននឹងយល់យ៉ាងច្បាស់អំពីទំនាស់ផ្សេងៗ និង តុលាការខ្មែរតាមបែបប្រពៃណីរួមមាន វិធីសាស្ត្រក្នុងការដោះស្រាយទំនាស់ បុគ្គលិកលក្ខណៈរបស់អ្នកកាត់ក្ដី យុត្តិធម៌និងអយុត្តិធម៌។ ក្នុងទីនេះ ទំនាស់ភាគច្រើននៅក្នុងរឿងច្រើនទាក់ទងទៅនឹងជីវភាពរស់នៅរបស់មនុស្សនៅក្នុងសង្គម ហើយសំខាន់កើតចេញពីការបាត់បង់ផលប្រយោជន៍ ការមិនយោគយល់គ្នា និងការលោភលន់របស់តួអង្គនិមួយៗ។ ចំណែកតុលាការវិញមានពីរប្រភេទ គឺតុលាការកាត់ក្ដីពុករលួយស៊ីសំណូកសូកប៉ាន់ ដោយកាត់សេចក្ដីឲ្យអ្នកអាក្រក់ទៅជាឈ្នះឲ្យអ្នកល្អទៅជាចាញ់ និងតុលាការកាត់ក្ដីដោយភាពយុត្តិធម៌ មិនលំអៀងដោយអំណាច ឬដោយប្រការណាមួយឡើយ គឺកាត់ក្ដីដោយផ្អែកលើភស្តុតាងហេតុផលច្បាស់លាស់ កាត់ក្ដីឲ្យអ្នកដែលប្រព្រឹត្តអាក្រក់ត្រូវតែទទួលទោស អ្នកធ្វើល្អត្រូវតែឈ្នះ។

អ្វីដែលគួរចាប់អារម្មណ៍ជាងគេនៅទីនេះគឺទំនាស់នៅក្នុង*រឿងភេតិរ* ដែលកើតឡើងដោយសារការលោភលន់និងការមិនយោគយល់គ្នារបស់តួអង្គភេទាំងពីរដែលជាមិត្តនឹងគ្នា។ ភេទាំងពីរនេះខិតខំរកត្រីមក តែមិនបានស៊ីត្រីនោះទេ ពីព្រោះតែវាបែងចែកត្រីគ្នាមិនដាច់ស្រេច ហើយចង់ឈ្នះរៀងៗខ្លួន។ ទីបំផុតត្រីនោះបែរ

ជាបានទៅចចកដែលជាជួយអ្នកកាត់ក្តីអោយទៅវិញ។ នេះធ្វើឲ្យនឹកឃើញដល់សុភាសិតបុរាណមួយពោលថា "**ប្រាក់ក៏បង់ថង់ក៏ដាច**" ។ ធ្វូងតាមបទពិសោធន៍នេះ យើងយល់ថាប្រសិនបើមានបញ្ហាខ្វែងគំនិតគ្នាលើសលោះគ្នាបន្តិចបន្តួច យើងគួរតែចេះសម្រុះសម្រួលគ្នាដោយសន្តិវិធី អន់ឱនគ្នាទៅវិញទៅមកដើម្បីកុំឲ្យមានបញ្ហាវែងឆ្ងាយ ជាហេតុនាំឲ្យមានការខាតបង់ទាំងពេលវេលានិងទ្រព្យសម្បត្តិ។ ដូច្នោះវាអាចជាសញ្ញាមួយជួយដាស់អារម្មណ៍ដល់មនុស្សទូទៅឲ្យបានយល់ពីផលវិបាកដែលកើតឡើងពីជម្លោះ និងបានដឹងពីប្រភេទតុលាការណាដែលមិនមែនជាទីពឹងរបស់ខ្លួន។

ផ្ទុយទៅវិញយើងក៏មានរឿងព្រេងជាច្រើនដែលចុះបញ្ចាំងពីកាត់ក្តីប្រកបដោយគតិយុត្តិធម៌ដល់សង្គមនិងប្រជាជនផងដែរ។ ទោះបីជារឿងទាំងនោះដំបូងឡើយបង្ហាញពីការកាត់ក្តីអយុត្តិធម៌យ៉ាងណាក៏ដោយក៏ទីបំផុតជនរងគ្រោះអាចរកអ្នកកាត់ក្តីដោយយុត្តិធម៌ជាទីពឹងសម្រាប់ខ្លួនបាននៅទីបញ្ចប់នៃរឿង។ ត្រង់នេះមានមានន័យថា រឿងព្រេងបានផ្តល់នូវក្តីសង្ឃឹមដល់អ្នកស្លូតត្រង់គ្រប់គ្នាថា អាចនឹងទទួលបាននូវភាពយុត្តិធម៌ហើយអំពើយុត្តិធម៌ត្រូវតែឈ្នះអំពើអយុត្តិធម៌ មិនខុសពីព្រះធម៌ដែលព្រះពុទ្ធអង្គទ្រង់បានសម្តែងមកហើយថា "អ្នកដែលសាងល្អទទួលបានផលល្អ អ្នកដែលសាងអាក្រក់ទទួលបានផលអាក្រក់" នោះទេ។

ដូច្នេះ សង្គមគ្រួសារក៏ដូចសង្គមជាតិដែររមែងត្រូវការយុត្តិធម៌ និងសច្ចៈធម៌ជាចាំបាច់។ យុត្តិធម៌កើតចេញមកពីធម៌ ពោលគឺសេចក្តីស្រឡាញ់ស្មើៗគ្នា ភាពស្មោះត្រង់ ភាពមិនលំអៀងដោយសារទ្រព្យសម្បត្តិអំណាច បុណ្យសក្តិ ឬបក្សពួកនោះឡើយ។

ឆ្លៀតក្នុងឱកាសនេះ យើងខ្ញុំជាសមាជិកស្រាវជ្រាវទាំងអស់ តំណាងឲ្យវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

ទាំងមូល សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ស្ថានទូតអាមេរិកប្រចាំនៅព្រះរាជាណាចក្រកម្ពុជាដែលបានផ្ដល់ថវិកាទ្រទ្រង់ការស្រាវជ្រាវនេះ។ ព្រមជាមួយគ្នានេះយើងខ្ញុំក៏សូមថ្លែងអំណរគុណដល់អ្នកផ្ដល់បទសម្ភាសន៍ទាំងអស់ ជាពិសេសលោកតាលោកយាយដែលបានចំណាយពេលវេលាក្នុងការនិទានរឿងព្រេងទាំងនេះនិងចែករំលែកបទពិសោធន៍របស់ខ្លួន។

សូមឧទ្ទិសស្នាដៃនេះ ដល់អ្នកមានគុណទាំងឡាយ និងសូមប្រសិទ្ធពរជ័យដល់អ្នកទាំងអស់នូវពុទ្ធពរទាំង៥ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ បដិភានៈ គ្រប់ប្រការ។ សូមឲ្យស្នាដៃនេះក្លាយជាប្រយោជន៍ដល់សាធុជននិងអ្នកជំនាន់ក្រោយទាំងឡាយ ។

សមាជិកស្រាវជ្រាវគម្រោងរឿងព្រេងខ្មែរថ្មី
វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

# ១- រឿងស្ត្រីពីរនាក់ដណ្ដើមផ័ត្រគ្នា

**និទានដោយលោកអ៊ុំ ស៊ឹម ផូ [១]**

*- លោកពូឥឡូវបង្វែរមករឿងដែលទាក់ទងនឹងមនុស្សម្ដង ដូចជារឿងមានមនុស្សស្រី២នាក់ដណ្ដើមកូនគ្នា លោកពូចេះទេ?*

*- អូមើល! អេ អាហ្នឹងទាក់ទងរឿងព្រះ រឿងព្រះមហោសថ។ អេ ខ្ញុំចាំមិនសូវបានសោះ! រឿងហ្នឹងដូចជាកើតតាំងពីសម័យព្រះ ព្រះសមណគោត្តមកើតជាព្រះមហោសថឯណោះ តាំងពីព្រះសមណគោត្តមមិនទាន់មានឯណោះ! អេ តាមខ្ញុំចាំរឿងហ្នឹងដូចជារឿងស្ត្រីពីរនាក់ដណ្ដើមឆ័ត្រគ្នាទេ។ រឿងហ្នឹងដូចថា៖*

*មាននាងម្នាក់ហ្នឹងទទូរឆ័ត្រមក ដល់ទទូរឆ័ត្រមក មានភ្លៀងធ្លាក់។ នាងម្នាក់ទៀតថា៖ " សុំទទូរផង! "*

*តែនាងនោះតបថា៖ " ទេ! អញអត់ឲ្យទទូរឆ័ត្រអញទេ! "*

*នាងម្នាក់នោះខឹងណាស់ ដល់ទៅវាដើរទៅកៀកនាងនោះ ហើយក៏ដណ្ដើមឆ័ត្រពីនាងម្នាក់នោះ រហូតដល់រហែកឆ័ត្រហ្នឹងណ៎ា។ រហែកឆ័ត្ររួចហើយក៏កើតរឿងឈ្លោះគ្នា។ អាមួយថារបស់អាមួយ ឯអាមួយទៀតថារបស់អាមួយទៀត។ មិនសុខចិត្ត ទាំងពីរនាក់ក៏នាំគ្នាទៅរកព្រះមហោសថឲ្យកាត់សេចក្ដី។*

*ព្រះមហោសថសួរសំណួរថា៖ " តើអ្នកណាជាម្ចាស់ឆ័ត្រ? "*

---

១ *ភូមិហនុមាន ឃុំក្រាំងធ្នុង ស្រុកបាទី ខេត្តតាកែវ*

អាមួយគេថា៖ "ខ្ញុំ! "

អាមួយទៀតគេថា៖ " ឆ័ត្រអញទេ! "

ព្រះមហោសថជាអ្នកកាត់ក្តីរកអត់ឃើញភ្លាមៗទេ ព្រះមហោក៏រកផ្លូវស្កាត់វិញ។

ព្រះមហោសួរទៅនាងម្នាក់ថា៖ " ផ្ទះអ្នកឯងនៅឯណា! "

រួចព្រះមហោសឲ្យមនុស្សម្នាក់ទៅតាម ហើយឲ្យនាងនោះកាន់ឆ័ត្រទៅរកផ្ទះនាង។ ពេលទៅដល់ កូននាងមិនមែនម្ចាស់ឆ័ត្រគឺកូនម្ចាស់ផ្ទះវាអត់ដែលមានឆ័ត្រណាស់ ក៏សួរម្ដាយវាថា៖ " យីអើ! ម៉ែបានឆ័ត្រមកពីណាវហែកហ្នឹង? "

លឺដូច្នេះ គេក៏យកឆ័ត្រត្រលប់មកវិញ ហើយនាំទៅផ្ទះនាងម្នាក់ទៀត ម្នាក់ដទៃទៀតណាស់!

ពេលទៅដល់ អាកូននាងនោះវាឃើញវាស្គាល់ឆ័ត្រវាក៏ស្រែកសួរ៖ " ម៉ែចឆ័ត្រយើងរហែកអញ្ចឹងហើយម៉ែ!

ពេលនោះទើបរកឃើញម្ចាស់ឆ័ត្រ ៕

# ២- រឿងខ្ចីលុយសេដ្ឋី

**និទានដោយ: លោកតា ឆាយ កង [២]**



២ ភូមិអង្គតាច័ន្ទ ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ

មានបុរសម្នាក់ទៅខ្ចីលុយសេដ្ឋី ។ គាត់សន្យាថាខែពីរនឹងសងសេដ្ឋីវិញ ។ លុះដល់គ្រប់ខែពីរ សេដ្ឋីទៅទារលុយបុរសនោះ តែគាត់អត់ឲ្យ ។ ទោះបីសេដ្ឋីទៅទារជាញយៗ ក៏បុរសនោះនៅតែមិនឲ្យទៀត ។

សេដ្ឋីនិយាយថា៖ "ចុះម៉េចបានជាដល់ខែពីរ ហើយនៅតែពុំព្រមឲ្យទៀត? "

បុរសនោះតបថា៖ " ខែមានតែមួយទេតើ មិនមានឃើញខែពីរឯណា? ចុះឲ្យខ្ញុំសងយ៉ាងម៉េច? "

សុភាទន្សាយឮអ្នកទាំងពីរជជែកគ្នា ក៏លូកមាត់ថា៖ " បើអញ្ចឹង ទៅអ្នកឯង! ទៅធ្វើពានទៅលើទឹកទៅចាំខ្ញុំទៅកាត់ក្ដីឲ្យ! "

ដល់ពេលកាត់ក្ដីមកដល់ គេប្រជុំគ្នាក្នុងពានដែលសង់លើទឹកនោះ។

សេដ្ឋីរ៉ាយរាប់ថា៖ "ឥឡូវខែពីរខែបីហួសទៅហើយ អ្នកឯងសន្យាសងលុយនៅខែពីរ ដល់ខែពីរហើយម៉េចមិនសងអញ្ចឹង? "

បុរសឆ្លើយថា៖ " ឥឡូវខែមានតែមួយ ខ្ញុំម៉េចនឹងសង? "

សុភាទន្សាយតបទៅបុរសនោះថា៖ " ចុះពីលើអ្នកឯងមានខែមួយ ហើយអ្នកឯងមើលទៅក្រោមមានខែមួយទៀតទេ?

បុរសនោះឆ្លើយថា៖ " មានខែមួយទៀតមែនៗ "

សុភាទន្សាយពោលថា៖ " អញ្ចឹងខែពីរហើយ បុរសឯងត្រូវសងលុយគេទៅ! " ។

# ៣- រឿងបុរសពីរនាក់ដាក់អន្ទាក់សត្វ

និទានដោយៈ លោកតា ឆាយ កង



មានមិត្តពីរនាក់បបួលគ្នាទៅដាក់អន្ទាក់សត្វ។ បុរសទាំងពីរដើរទៅដល់ដើមឈើមួយដែលមានជ្រូកព្រៃធ្លាប់មកស៊ីផ្លែជារៀងរាល់ថ្ងៃ ។ មិត្តមួយដាក់អន្ទាក់នៅនឹងដី រីឯមិត្តម្នាក់ទៀតដាក់នៅចុងឈើ ។ ដាក់រួចហើយមិត្តទាំងពីរសន្យាគ្នាថា យើងឡើងមកមើលអន្ទាក់ជំណាលគ្នា មិនឲ្យអ្នកណាមកមុនមកក្រោយទេ!

ក្រោយពេលទៅដល់ផ្ទះ អ្នកដែលដាក់អន្ទាក់សត្វនៅចុងឈើលួចមកមើលអន្ទាក់មុន។ បុរសនោះឃើញជ្រូកជាប់អន្ទាក់បុរសដែលដាក់នៅគល់ឈើ ហើយក៏ដោះជ្រូកទៅដាក់នៅអន្ទាក់ខ្លួនឯងចុងឈើទៅ ។ លុះបុរសនោះធ្វើការរួចរាល់ហើយ ក៏វិលត្រឡប់ទៅផ្ទះវិញ ទៅដាស់ម្នាក់ទៀតឲ្យមកមើលអន្ទាក់។ បុរសដាក់អន្ទាក់នៅគល់ឈើឃើញសត្វជ្រូកបែរទៅជាជាប់អន្ទាក់របស់បុរសដាក់នៅចុងឈើទៅវិញ កើតរឿងជជែកទាស់ទែងគ្នា ។

បុរសនោះមិនសុខចិត្តពោលថា៖ " អ្នកឯងដាក់អន្ទាក់នៅចុងឈើសោះ ហេតុអ្វីក៏ទៅជាប់សត្វជ្រូកទៅវិញ? "

បុរសម្ចាស់អន្ទាក់នៅគល់ឈើមិនសុខចិត្ត ដើរទៅរកស្មារក្ដី។ លុះដើរៗទៅ គាត់ក៏បានទៅជួបសុភាទន្សាយជាសត្វតូចតែ និងមានប្រាជ្ញាវាងវៃ ។

សុភាទន្សាយសួរថា៖ " ហេ! បងចង់ទៅណាហ្នឹង? "

បុរសនោះតបវិញថា៖ " ខ្ញុំត្រូវចាញ់បោកគេ! "

សុភាទន្សាយសួរថា៖ " ចាញ់បោកយ៉ាងម៉េច? "

បុរសរៀបរាប់តាមដំណើររឿងថា៖ " យើងខ្ញុំទាំងពីរនាក់បានទៅដាក់អន្ទាក់ គេឲ្យខ្ញុំដាក់នៅដី ហើយគេ

ដាក់នៅលើចុងឈើ ស្រាប់តែពេលមកមើលអន្ទាក់ ឃើញសត្វជ្រូកបែរជាទៅជាប់អន្ទាក់នៅចុងឈើទៅវិញ ខ្ញុំមិនសុខចិត្តក៏ដើររកស្មារក្តី[៣]។"

សុភាទន្សាយតបវិញថា៖ "មិនអីទេ ចាំខ្ញុំជួយ ឲ្យតែបានចេកស្ងួន[៤]មួយស្និត ខ្ញុំនឹងកាត់ក្តីឲ្យ! "

ចំណែកខាងបុរសដាក់អន្ទាក់នៅចុងឈើក៏មានស្មារក្តីដែរ។ ដល់វេលាត្រូវមកកាត់ក្តី សុភាទន្សាយមកយឺត ធ្វើឲ្យខាងបុរសអន្ទាក់នៅចុងឈើនិងស្មារក្តីរង់ចាំអស់មួយព្រឹកធំ ទើបឃើញសុភាទន្សាយមក។

ពេលសុភាទន្សាយមកដល់ ស្មារក្តីខាងបុរសដាក់អន្ទាក់ចុងឈើសួរថា៖ " ចុះបងសុភាទន្សាយម៉េចក៏យូរម្ល៉េះ? "

សុភាទន្សាយថា៖ "ទេ! អាយូរហ្នឹងមកពីចង់មើលត្រីក្រាញ់ឡើងស៊ីស្លឹកអំពិលត្រួយអំពិល! "

ឮដូចនេះ ស្មារក្តីម្ខាងទៀតឆ្លើយថា៖ " មិនដែលមានត្រីក្រាញ់ណាឡើងទៅស៊ីត្រួយអំពិលបានទេ? "

សុភាទន្សាយក៏ឆ្លើយតបវិញថា៖ " ហើយចុះមិនដែលមានជ្រូកឯណាឡើងទៅជាប់អន្ទាក់នៅចុងឈើ? មានតែជាប់អន្ទាក់គេនៅដី គឺអ្នកឯងទេដែលដោះយកទៅដាក់នៅចុងឈើវិញនោះ! "

ឮដូចនេះ ខាងបុរសដាក់អន្ទាក់ចុងឈើចាញ់បញ្ញាសុភាទន្សាយ។ រីឯសត្វជ្រូកនោះក៏បានទៅខាងបុរសដាក់អន្ទាក់នៅគល់ឈើវិញទៅ ៕

---

៣ មានន័យថាអ្នកកាន់ក្តី។

៤ តាមវចនានុក្រមខ្មែរ មានតែពាក្យ "ចេកនួន" ។ ចេកស្ងួននេះប្រហែលក្លាយមកពីចេកនួននេះឯង។ ឥឡូវនេះ ពាក្យនេះប្រជាជនតាមជនបទនិយមហៅថាចេកស្ងួនជំនួសពាក្យ ចេកនួនទៅវិញ។

# ៤- រឿងភេពីរ

## និទានដោយៈ អាចារ្យ អន [៥]



៥ ភូមិចិនដាំម្ទូ ឃុំរាំងចាស់ ស្រុកឧត្ដុង ខេត្តកំពង់ស្ពឺ

មានរឿងតំណាលថា ក្អែកពីរជាមិត្តភក្តិនឹងគ្នាហើយតែងតែរកស៊ីចូលគ្នា។ ក្អែកមួយរកស៊ីនៅទឹកជ្រៅ ក្អែកមួយរកស៊ីចាប់ត្រីក្នុងទឹករាក់ ។ ពេលចាប់ត្រីបានមក ក្អែកទាំងពីរនិយាយគិតគូរនឹងចែកគ្នា ។

ក្អែកទឹករាក់ពោលថា៖ " ឥឡូវពាក់កណ្ដាលខ្លួនមកក្បាលត្រូវបានមកអញ ចំណែកឯងនៅទឹកជ្រៅត្រូវបានកន្ទុយចុះ ព្រោះឯងចេះហែល! "

ក្អែកទាំងពីរនោះទាស់ទែងគ្នាមិនព្រមរៀងៗខ្លួន ក៏យកត្រីទៅរកអ្នកកាត់ក្តី។ ក្អែកទាំងពីរទៅជួបឆ្កែចចក ។

ចចកសួរថា៖ " តើឯងទាំងពីរនាក់នេះទៅណា? "

ក្អែកទាំងពីរឆ្លើយថា៖ " ខ្ញុំទៅរកអស់លោកអ្នកប្រាជ្ញដើម្បីកាត់ក្តី ព្រោះខ្ញុំទាំងពីរនេះចាប់ត្រីបានពីក្នុងទឹក ហើយចែកគ្នាមិនដាច់ស្រេច ម្នាក់ចង់ដណ្តើមពាក់កណ្តាលខ្លួនមកក្បាល ម្នាក់ចង់ដណ្តើមពាក់កណ្តាលខ្លួនមកកន្ទុយ តែមិនដឹងកាត់ចែកយ៉ាងណាឲ្យស្មើគ្នា? "

ក្អែកទឹកជ្រៅនិយាយទៅកាន់ក្អែកទឹករាក់ថា៖ " នែ! ឯងនៅទឹករាក់ត្រូវបានផ្នែកខាងកន្ទុយ ឯអញវិញនៅទឹកជ្រៅអញត្រូវយកពីត្រឹមពាក់កណ្តាលខ្លួនទៅខាងក្បាលទើបត្រូវ! "

ចចកស្តាប់ក្អែកទាំងពីររៀបរាប់ ក៏និយាយឡើងថា៖ " បើអញ្ចឹងយកត្រីមក អញនឹងកាត់ឲ្យ! "

ចចកបន្ថែម៖" ឥឡូវចាំបន្តិចណ៎ា! ខាងក្បាលកាត់ត្រឹមនេះទៅ ឯខាងកន្ទុយកាត់ត្រឹមតែកន្ទុយរលាស់ៗនោះទៅ ។ អ្នកណាចង់បានក្បាលយកឆ្អឹងក្បាលទៅ អ្នកណាចង់បានកន្ទុយយកកន្ទុយត្រឹមតែបក់ៗហ្នឹងទៅ! "

ចចកកាត់ក្បាលកន្ទុយត្រីឲ្យក្អែកទាំងពីរ ហើយវាយកសាច់កណ្តាលទាំងអស់ជារបស់ខ្លួនទៅ ៕

# ៥- រឿងចចក

និទានដោយៈ លោកយាយ ហួន [៦]



៦ ភូមិឃ្លាំងប្រាំយុំរាំងចាស់ ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ

កាលពីព្រេងនាយ នៅថ្ងៃមួយនាខែកត្ដិក មានសត្វចចកមួយដើររកចាប់ត្រីធ្វើជាអាហារ។ កាលវាកំពុងដើរទៅដើរមក ស្រាប់តែប្រទះឃើញថ្លុកមួយដែលមានកំពឹសជាច្រើនកំពុងលោតផ្លោតៗ ។

គ្រាន់តែឃើញចចកភ្លាម កំពឹសស្រែកជេរថា៖ " អាម៉ែចចក កំពៅកំពឹសនៅផ្លូវពុំព្រមស៊ី! "

ចចកតបថា៖ " អញស៊ីឯងយ៉ាងម៉េចទៅ? បើពួកឯងប្រលាក់សុទ្ធតែភក់! "

កំពឹសបានឆ្លើយថា៖ " អ្នែងប្រះខ្លួននទៀលមក អញនឹងតោងរោមអ្នែង ហើយឯងនាំពួកយើងទៅរកទឹកត្រពាំងណាដែលជ្រៅ ដើម្បីលាងពួកអញឲ្យស្អាតរួចសឹមស៊ីពួកអញ! "

ចចកក៏យល់ព្រម។ បានឱកាសកំពឹសក៏នាំគ្នាតោងរោមចចក ។ ចចកនឹកអរក៏បោលចេញយ៉ាងលឿនឆ្ពោះទៅរកត្រពាំងដែលមានទឹកជ្រៅ។

ពេលចចកកំពុងបោលតាមផ្លូវ កំពឹសខ្លាចធ្លាក់ក៏ស្រែកប្រាប់ចចកថា៖ " ឯងកុំបោលលឿនពេកប្រយ័ត្នជ្រុះអញខានស៊ី ! "

ចចកយល់ព្រម បន្ថយល្បឿន។

ចចកដើរយូរៗទៅ ក៏ឃើញត្រពាំងមួយដែលមានទឹកជ្រៅ ។ ចចកដើរចូលទៅក្នុងត្រពាំងរហូតដល់បានត្រឹមក កំពឹសឃើញឱកាសល្អ ក៏នាំគ្នាហែលគេចបាត់អស់ទៅ ។

ចចកភ្ញាក់ព្រើតហើយលាន់មាត់ថា៖ " អូ! អញចាញ់បោកពួកកំពឹសទេតើ! "

ចចកខឹងយ៉ាងខ្លាំង រួចហើយបានដើរបបួលគ្នីគ្នា មានទុង ពស់ ត្រំ អក ដំរី ទុង ទោច ខ្លានិងសត្វជាច្រើន

ទៀតមកជួយបាចទឹកអោយរីងដើម្បីចាប់កំពឹសនិងមច្ឆាជាតិផ្សេងៗស៊ីជាអាហារ។ ពស់ថ្លាន់មានតួនាទីជាអ្នកធ្វើទំនប់ រីឯដំរីនិងសត្វដទៃទៀតជាអ្នកបាចទឹកត្រពាំងឲ្យរីង ។ លុះបាចយូរទៅ មច្ឆាជាតិទាំងអស់ក្នុងត្រពាំងនាំគ្នាភ័យតោឡោជាខ្លាំង ។

ត្រីក្រាញ់និយាយទៅកាន់ក្រុមមច្ឆាថា " បើពួកវាចកនៅតែបាចដូច្នេះទៀត យើងច្បាស់ជាស្លាប់មិនខាន! មានតែយើងទៅពឹងបងទន្សាយឲ្យជួយដោះទុក្ខយើងទើបបាន!"

គិតរួចហើយ ត្រីក្រាញ់ធ្វើដំណើរចេញទៅហើយក៏ជួបទន្សាយនៅក្នុងព្រៃមួយ ។

ឃើញទន្សាយភ្លាម ត្រីក្រាញ់និយាយថា៖ " បងទន្សាយអើយ! គេបាចទឹកត្រពាំងរីងអស់ហើយ មានទាំងដំរី ពស់ថ្លាន់ ទុង ទោច មកពពាក់ពពូនច្រើនណាស់។ បងឯងគិតមើល! បើត្រពាំងរីងអស់ បងឯងបានទឹកអីពិសារ? "

ឮដូច្នោះ ទន្សាយយល់ព្រមជួយយកអាសារ ហើយប្រញាប់ធ្វើដំណើរយ៉ាងលឿនឆ្ពោះទៅត្រពាំង ។ នៅតាមផ្លូវទន្សាយឃើញស្លឹកកណ្ដោលមួយដែលមានដង្កូវស៊ីចោះក្រវេមក្រវាម ក៏បេះកាន់ដើរទៅ ។

លុះទៅដល់មាត់ត្រពាំង ទន្សាយស្រែកទៅកាន់ហ្វូងសត្វដែលកំពុងបាចទឹកថា៖ " នែ ពួកអ្នកបាចទឹកត្រពាំងទាំងឡាយ ដឹងទេត្រពាំងនេះ ព្រះឥន្ទ្រចាត់ឲ្យខ្ញុំចាំ ឥឡូវខ្ញុំទទួលសារពីព្រះឥន្ទ្រមកទាំងអស់គ្នាចាំស្ដាប់ ខ្ញុំនឹងសូត្រសារនេះឲ្យស្ដាប់ កាច់ជើងត្រី ប្រមុំជើងអក កាត់ក្បាលក្ដែបចក ដកភ្លុកដំរីស !"

ដំរីសគ្រាន់តែឮថា ដកភ្លុករបស់ខ្លួនក៏បោលក្អួង ស្ទុះទៅជាន់ពស់ថ្លាន់ដាច់ធ្លាយទំនប់ ផ្អើលដល់សត្វ

ដទៃទៀតរត់ជាន់គ្នាពាសពេញ។ សត្វខ្លះទៀតរត់គេច ឯខ្លះទៀតលិចលង់ស្លាប់អស់ទៅ ។ សត្វទាំងអស់នោះក្លាយជាចំណីក្រុមមច្ឆានិងកំពឹសវិញ។ ពួកកំពឹសនិងមច្ឆាជាតិក៏រស់នៅយ៉ាងសុខសាន្តក្នុងត្រពាំងចាប់ពីពេលនោះទៅហោង ៕

# ៦- រឿងសេដ្ឋី និងបុរសឆ្លាត

និទានដោយ: លោកតា ឆាយ កង



កាលពីព្រេងមានសេដ្ឋីម្នាក់មានកូនក្រមុំមួយ ។ សេដ្ឋីនោះបានប្រកាសថាបើបុរសណាអាចដេកត្រាំក្នុងទឹកបានមួយយប់ទល់ភ្លឺ គាត់នឹងលើកកូនក្រមុំឲ្យបុរសនោះ។

មានបុរសម្នាក់បានស្ម័គ្រចិត្តឆ្លើយថា៖ "ខ្ញុំអាចដេកត្រាំក្នុងទឹកបានមួយយប់ទល់ភ្លឺ។"

សេដ្ឋីបង្គាប់ឲ្យបុរសនោះទៅដេកត្រាំទឹកក្នុងត្រពាំងរបស់គាត់។

លុះដល់ឃើញបុរសនោះអាចដេកត្រាំទឹកបាន តាំងពីព្រលប់ហូតដល់ទៀបភ្លឺដូច្នេះ សេដ្ឋីក៏នឹកស្ដាយក្នុងចិត្តថា៖ " កូនក្រមុំរបស់អញប្រាកដជាបានទៅបុរសនោះមិនខាន" ។

សេដ្ឋីនឹកឃើញមធ្យោបាយមួយ គាត់បង្គាប់ឲ្យពួកបាវព្រាវជញ្ជូនចំបើងយកទៅដុតនៅមាត់ត្រពាំង ។

លុះភ្លឺឡើងបុរសបានងើបពីក្នុងត្រពាំង ហើយក៏ទៅទាមទារយកកូនក្រមុំពីសេដ្ឋីតាមការសន្យា។

សេដ្ឋីប្រកែកថា៖ " អ្នកឯងមកទារយកកូនក្រមុំខ្ញុំម្ដេចនឹងបាន! ពេលអ្នកឯងដេកត្រាំក្នុងទឹកនោះ បើកុំតែបានខ្ញុំយកភ្លើងទៅដុតនៅមាត់ត្រពាំងឲ្យក្ដៅ ម្ល៉េះសមអ្នកឯងរងាស្លាប់បាត់ទៅហើយ! "

ព្រោះដូច្នោះ បុរសនោះកើតទុក្ខមិន សុខចិត្ត ហើយពុនចេកមួយស្និតដើររកអ្នកប្រាជ្ញឲ្យជួយដោះស្រាយរឿងនេះ ។ លុះដើរៗទៅបានជួបនឹងសុភាទន្សាយ ។

សុភាទន្សាយក៏ស្រែកសួរ៖ " យីបងមនុស្សលោកដើរទាំងយំសស្រោក់ទៅណា? មានចេកមួយស្និតពុនផង! "

បុរសនោះក៏រៀបរាប់ថា៖ " ខ្ញុំនឹកទៅដូចជាចាញ់ប្រាជ្ញាលោកសេដ្ឋី ព្រោះបានសន្យាគ្នាពីមុនថា បើខ្ញុំអាចដេកត្រាំក្នុងទឹកបានមួយយប់ទល់ភ្លឺ គាត់នឹងលើកកូនក្រមុំឲ្យ! លុះដល់ភ្លឺស្រាងៗនៅទិសខាងកើត លោក

សេដ្ឋីបង្គាប់ឲ្យពួកបាវព្រាវយកចំបើងទៅដុតនៅមាត់ត្រពាំង ។ នៅពេលថ្ងៃរះឡើង ខ្ញុំក្រោកពីក្នុងទឹកមក ហើយទៅទារយកកូនក្រមុំតាមពាក្យសន្យា ស្រាប់តែលោកសេដ្ឋីប្រកែកថា កុំតែបានគាត់ដុតភ្លើងឲ្យបាត់រងា កុំអីខ្ញុំស្លាប់ក្នុងទឹកបាត់ទៅហើយ! ឥឡូវនេះខ្ញុំកំពុងដើររកអ្នកជួយកាត់ក្ដីឲ្យ សូមបងសុភាទន្សាយជួយខ្ញុំផង! ខ្ញុំជូនបេកមួយស្និត! "

សុភាទន្សាយជានាខ្លួនជួយដោះស្រាយរឿងនេះ ។ សុភាទន្សាយបង្គាប់ឲ្យបុរសនោះរៀបចំបាយសម្ល ដាក់លើតុ តែពេលស្លមិនឲ្យបង់អំបិលទេ គ្រាន់តែយកអំបិលដាក់ក្រោមចានសម្លទៅបានហើយ ។ សុភាទន្សាយនាំបុរសនោះទៅជួបសេដ្ឋី ហើយបុរសនោះក៏បានរៀបចំបាយសម្លតាមបង្គាប់របស់សុភាទន្សាយ ជូនសេដ្ឋីពិសា ។

ពេលសេដ្ឋីហូបបាយហើយហុតទឹកសម្លមួយម៉ាត់ក៏លាន់មាត់ថា៖ " យី! សម្លនេះម៉េចមិនបង់អំបិលទេ? សាបម្ល៉េះ? "

ទន្សាយតបវិញថា៖ " ចុះចំបើងមួយគងយកទៅដុតនៅមាត់ត្រពាំង ធ្វើម្ដេចនឹងក្ដៅដល់ក្នុងទឹក? "

សេដ្ឋីទាល់ប្រាជ្ញា ចាញ់ក្ដីសុភាទន្សាយ ហើយក៏យល់ព្រមលើកកូនក្រមុំឲ្យទៅបុរសនោះទៅ ៕

# ៧- រឿងមហាឫសីប្រោសខ្លា

**និទានដោយៈ លោក ជា ជឿន [៧]**



៧ ភូមិថ្មី ឃុំរការគយ ស្រុកកងមាស ខេត្តកំពង់ចាម

សម័យថ្ងៃមួយមានព្រះមុនីឥសីមួយអង្គ ទ្រង់និមន្តដើរបង្គ្រមប្រុងទៅរកកន្លែងគង់ធ្វើសមាធិភាវនាធម៌ៗ ចៃដន្យនាពេលនោះលោកនិមន្តទៅ ក៏បានឃើញខ្លាមួយកំពុងដេកស្លាប់ដោយសារពស់ចឹកនៅជិតរូងពស់នោះៗ

ដោយសារព្រះមុនីឥសីមានចិត្តសប្បុរស ហើយចេះវិជ្ជាបន្សាបពិសពស់ផង លោកក៏មានព្រះទ័យចង់ជួយសង្គ្រោះដល់ខ្លានោះៗ លោកបានយកថ្នាំពិសពស់ គួបផ្សំជាមួយនឹងវេទមន្តព្យាបាលផងដែរនោះ ទើបធ្វើឲ្យខ្លាមានជីវិតឡើងវិញៗ លុះដល់ខ្លានោះដឹងខ្លួន រស់រានមានជីវិតឡើង វាបែរជាខឹងនឹងព្រះមុនីឥសីហើយចង់ស៊ីសាច់គាត់ៗ វាមិនបាននឹកដល់គុណព្រះមុនីឥសីទេ ដោយសារចិត្តវាលោភលន់ហើយខ្លួនវាឃ្លានផងៗ ម្យ៉ាងទៀតដោយយកលេសចោទប្រកាន់មុនីឥសីថា ខ្លួនវាកំពុងតែដេកលក់យ៉ាងសុខស្រួល ហេតុដូចម្តេចបានជាតាឥសីមកដាស់វាឲ្យភ្ញាក់ វាមិនសុខចិត្តទេ វានឹងស៊ីព្រះមុនីឥសីឥឡូវនេះហើយៗ

ព្រះមុនីឥសីរៀបរាប់ថា៖ " អ្នកឯងស្លាប់ដោយសារពស់ចឹក ខ្ញុំបានដាក់ថ្នាំពិសពស់ឲ្យអ្នកឯង គួបផ្សំនឹងវេទមន្តស្តោះផ្លុំរបស់ខ្ញុំផងទើបអ្នកឯងបានរស់រានមានជីវិតឡើងវិញ ខ្ញុំមិនមែនទៅដាស់ឯងទេ! "

ប៉ុន្តែដោយហេតុ សារជាតិខ្លាវាជាសត្វឃោរឃៅ មិនស្គាល់ហេតុផល ហើយជាសត្វរមិលគុណផង វានៅតែមិនព្រម គឺនៅតែចង់ស៊ីសាច់ព្រះមុនីឥសីទៀតៗ ព្រដូច្នោះព្រះមុនីឥសីមិនសុខចិត្តឲ្យខ្លាស៊ីទេ លោកខំដើររកអ្នកណាដែលមានប្រាជ្ញាបារមី និងគំនិត សច្ចៈ យុត្តិធម៌ដើម្បីនឹងជួយកាត់ក្តីរកយុត្តិធម៌អោយគាត់ៗ បើអំពើរបស់គាត់មិនត្រឹមត្រូវ គាត់សុខចិត្តឲ្យខ្លាស៊ី តែបើទង្វើហ្នឹងត្រឹមត្រូវសូមឲ្យតុលាការដែលជាអ្នកកាន់ជញ្ជីងហ្នឹងថ្លឹងឲ្យបានត្រឹមត្រូវៗ

លុះមុនីឥសីដើរៗទៅក៏ទៅជួបនឹងសុភាសេក។ ព្រះមុនីឥសីក៏ទៅប្ដឹងសុភាសេកដើម្បីឲ្យជួយធ្វើជាចៅក្រមកាត់ក្ដីរឿងរបស់ខ្លួនជាមួយនឹងសត្វខ្លា។ លុះដល់សុភាសេកស្ដាប់ដំណើរសេចក្ដីរបស់តាមុនីឥសីហើយក៏មានចិត្តលម្អៀងទៅរកខ្លា ព្រោះខ្លាចអំណាចខ្លាដែលជាសត្វសាហាវតែងតែគំរាមធ្វើទុកបុកម្នេញដល់ក្រុមគ្រួសាររបស់សុភាសេកមិនឲ្យមានសេចក្ដីសុខដល់កូនចៅ។

អញ្ចឹងសុភាសេកក៏សម្រេចកាត់សេចក្ដីថា៖ " តាឥសីឯងធ្វើអញ្ចឹងខុសហើយ គេកំពុងដេកលក់ស្រួលមិនត្រូវទៅដាស់រំខានគេទេ អញ្ចឹងត្រូវតែឲ្យខ្លាស៊ីទៅ! "

ព្កការកាត់សេចក្ដីបែបនេះ ព្រះមុនីឥសីមិនសុខចិត្តក៏សុំលាសុភាសេកទៅទៀត ទៅរកចៅក្រមណាដែលមានសន្ដានចិត្តឯករាជ្យ មិនឲ្យមានចិត្តលម្អៀងដោយសារខ្លាចអំណាចសត្វខ្លាឡើយ។

អញ្ចឹង គាត់ក៏បន្ដដំណើរទៅរកអ្នកកាត់ក្ដីផ្សេងទៀត។ លុះដើរទៅៗ គាត់បានជួបជាមួយនឹងសុភាទន្សាយ។ សុភាទន្សាយក៏សួរមុនីឥសីពីហេតុការណ៍ដែលកើតឡើងសព្វគ្រប់ហើយ វាក៏ប្រាប់ទៅមុនីឥសីថាឲ្យទៅរកចេកមួយស្និតមកអោយវា យើងនឹងជួយកាត់ក្ដីអោយ។ ព្ដូច្នោះ ឥសីក៏ប្រញាប់ប្រញាល់ទៅរកចេកឲ្យសុភាទន្សាយ។

បន្ទាប់ពីបានចេកហើយ មុនីឥសីក៏នាំសុភាទន្សាយទៅរកខ្លា។ សុភាទន្សាយក៏បង្គាប់ឲ្យសត្វខ្លាទៅដេកនៅកន្លែងដើមវិញ ដើម្បីឲ្យវាឃើញថាខ្លាដេកយ៉ាងម៉េចហើយឥសីធ្វើយ៉ាងម៉េចបានជាខ្លាភ្ញាក់។ ខ្លាក៏សុខចិត្តសុខកាយក៏ទៅដេកនៅត្រង់កន្លែងរន្ធពស់តាមការបង្គាប់របស់ទន្សាយ។ ពេលដែលខ្លាចូលទៅដេកភ្លាមនោះពស់ក៏ចេញមកចឹកខ្លាស្លាប់មួយរំពេច។ ដោយសារព្រះមុនីឥសីគាត់ជាអ្នកមានចិត្តសប្បុរសធម៌ មិនគិតពីរឿង

គំនុំ គាត់ក៏មានបំណងចង់ទៅប្រោះខ្លាហ្នឹងម្ដងទៀត ប៉ុន្តែដោយទន្សាយ គាត់អ្នកមានប្រាជ្ញាបាធិចេះប្ដឹងថ្លែងថាខ្លាជាអ្នកដែលរមិលគុណទៅហើយ ទោះបីថាធ្វើគុណយ៉ាងណាក៏ដោយក៏នៅតែមិនបានគុណវិញដែរ។ អញ្ចឹងវាក៏ប្រាប់តសីថាមិនបាច់ប្រោសខ្លានោះឡើងវិញទេទុកឲ្យវាដេកស្លាប់តែម្ដងទៅ។ អញ្ចឹងតាតសីហ្នឹងក៏បានរួចខ្លួនដោយសារសុកាទន្សាយជាអ្នកដែលមានប្រាជ្ញា បានជួយដោះស្រាយបញ្ហាដែលកើតឡើងដោយសារខ្លានោះប្រកបដោយយុត្តិធម៌ទៅហោង៕

# ៨- រឿងសុភាសិតតម្លៃសាមសិបតម្លឹង

និទានដោយៈ លោក ជា ជឿន



កាលពីព្រេងនាយ មានចៅមាណពម្នាក់រស់នៅក្នុងគ្រួសារមួយដែលមានជីវភាពក្រីក្រតោកយ៉ាកៗ ថ្ងៃមួយ បុរសនោះបានចេញទៅស្វែងរកគ្រូបាអាចារ្យដើម្បីរៀនយកវិជ្ជាសិល្ប៍សាស្ត្រ ក្រែងអាចយកចំណេះនេះមកចិញ្ចឹមជីវិតបាន។ ពេលបុរសនោះធ្វើដំណើរទៅ ក៏បានជួបនឹងលោកគ្រូអាចារ្យម្នាក់ហើយសុំស្នាក់នៅរៀនសូត្រជាមួយលោកគ្រូនោះ។ លោកគ្រូក៏សុខចិត្តយល់ព្រមជួយបង្ហាត់បង្រៀន។ ដោយចៅមាណពជាមនុស្សត្រង់ហើយគោតល្ងង់។ ពេលសិក្សាវិជ្ជាសីល្ប៍សាស្ត្រក្ដី វេទមន្តក្ដី ឬក៏អក្សរសាស្ត្រក្ដី គឺគាត់មានសតិបញ្ញាខ្សោយពិបាកក្នុងការចងចាំ មិនអាចចាប់យកបានទេ ប៉ុន្តែគាត់ជាមនុស្សចេះយកអាសារដឹងទុក្ខធុរៈ ចេះតបស្នងសងគុណ មើលខុសត្រូវ ទឹកក្ដៅ ទឹកត្រជាក់គោរពលោកគ្រូអាចារ្យ។

ដូច្នេះហើយលោកគ្រូអាចារ្យគិតថាមិនដឹងបានអីយកមកបង្រៀនចៅមាណពនោះ គាត់ក៏ឲ្យចៅមាណពរៀនទន្ទេញសុភាសិតបីឃ្លា ដោយក្នុងមួយឃ្លាៗមានតម្លៃ១០តម្លឹង អញ្ចឹងសុភាសិតបីឃ្លាហ្នឹងមានតម្លៃ៣០តម្លឹង។ គាត់ឲ្យមាណពទន្ទេញថា *បើឃ្លានណាស់កុំស៊ី បើងងុយណាស់កុំដេក បើចូលដំណេកកុំនិយាយនឹងស្រី។* ដូច្នោះសរុបទៅសុភាសិតទាំងបីឃ្លាហ្នឹងតម្លៃ៣០តម្លឹង។ ដោយមានរឿងនេះហើយបានជាគេដាក់ចំណងជើងថា*សុភាសិតតម្លៃ៣០សម្លឹង* នោះ។

លុះដល់មាណពរៀនចេះចាំសុភាសិតនោះហើយ គាត់ក៏បានសុំលាលោកគ្រូបាអាចារ្យធ្វើដំណើរត្រឡប់មកស្រុកទេសវិញដើម្បីជួបជុំប្រពន្ធកូន។ ពេលមាណពនោះធ្វើដំណើរមក ក៏បានមកដល់សមុទ្រយ៉ាងធំមួយដែលធ្វើអោយគាត់មិនអាចបន្តដំណើរទៅមុខទៀតបាន។ គាប់ចួនពេលនោះ មានសំពៅមួយមកពីស្រុក

ឆ្ងាយដើម្បីរកស៊ីជួញដូរបានបរកាត់ទីនេះ។ មាណពឃើញដូច្នោះក៏បោយដៃស្រែកហៅនាយម្ចាស់សំពៅឲ្យចូលអែបច្រាំងមកជួយចំលងខ្លួនគាត់ផង។ នាយសំពៅក៏បានអែបសំពៅចូលមករកច្រាំង រួចក៏នាំបុរសទៅជាមួយផងដែរ។ វេលាយប់មកដល់ ពួកអ្នកធ្វើដំណើរតាមសំពៅទាំងអស់ក៏នាំគ្នាហូបចុកយ៉ាងសប្បាយរីករាយ។ គេក៏ហៅមាណពឲ្យមកហូបចុកនឹងគេដែរ តែគាត់មិនព្រមទៅទេ ព្រោះនឹកដល់សុភាសិតដែលគាត់រៀនទន្ទេញចាំមាត់ពីលោកគ្រូ។ ទោះបីឃ្លានខ្លាំងក៏ដោយ ក៏បុរសនោះនឹកដល់បណ្ដាំគ្រូដែលថា *បើឃ្លានណាស់កុំអាលហូប* ជានិច្ច។

គាត់គិតថា៖ " អញ្ចឹងអញកុំស៊ីអី ព្រោះគ្រូផ្ដាំថាអញ្ចឹង!"

ចំណែកឯ អ្នកទាំងអស់នោះវិញនាំគ្នាហូបចុកស៊ីផឹកយ៉ាងសប្បាយ ខ្លះក៏ស្រវឹង ខ្លះក៏ឆ្អែតហល់ស្កប់ស្កល់ដេកលក់អស់ទៅ។ ទោះបីមាណពឃ្លានខ្លាំងរហូតដល់ចេញទឹកមាត់ធាវៗក៏ដោយ គាត់នៅតែខិតខំទន្ទេញសុភាសិតដើម្បីបន្ធូបការឃ្លាននិងមិនឲ្យងងុយគេង។

ចួនជាពេលនោះ មានយក្សមួយហោះនៅលើអាកាស វាក្រឡេកឃើញសំពៅហ្នឹងសុទ្ធតែមនុស្ស វានឹកឃ្លានសាច់មនុស្ស វាក៏ចុះពីលើអាកាសមកក្នុងសំពៅនេះ។ វាប្រុងនឹងចាប់ស៊ីមនុស្សដែលកំពុងតែស្រវឹងដេកលក់ស្កប់ស្កល់ ដោយសារពុលបាយ ពុលស្រា។ ទទួលជាពេលនោះពុកមាត់របស់យក្សក៏ធ្លាក់មកប៉ះលើមាណពដែលកំពុងអង្គុយទន្ទេញសុភាសិត។ មាណពក្រឡេកទៅឃើញយក្សភិតភ័យយ៉ាងខ្លាំង មិនដឹងធ្វើម៉េច ក៏ចាប់ពុកមាត់យក្សហ្នឹងជាប់។

ដល់ពេល មាណពចាប់ពុកមាត់យក្សជាប់ដូច្នោះ យក្សរើមិនរួចក៏ភ័យយ៉ាងខ្លាំង ហើយសុំអង្វរមាណព

ថា ៖ " សូមកុំសំលាប់ខ្ញុំ កុំធ្វើបាបខ្ញុំ កុំវាយខ្ញុំ កុំដកពុកមាត់ខ្ញុំ ខ្ញុំនឹងឲ្យលោកធ្វើជាម្ចាស់របស់ខ្ញុំ ហើយខ្ញុំនឹងប្រទានខ្សែរចង ដំបងវាយ និងផ្ទាំងថ្មិនឯងឲ្យលោកជារង្វាន់! " ឮការសន្យារបស់យក្សដូច្នោះ ចៅមាណពក៏ព្រមដោះលែងយក្សនោះអោយត្រលប់ទៅនគរវាំវិញ។ យក្សអរណាស់ក៏ហោះស្ទុះចេញបាត់ទៅ ។

លុះភ្លឺឡើង មាណពក៏យកហេតុការណ៍ទាំងអម្បាលម៉ានដែលកើតឡើងកាលពីយប់មិញ ទៅរ៉ាយរ៉ាប់ប្រាប់អ្នកធ្វើដំណើរ នៅលើសំពៅទាំងអស់។ ម្ចាស់សំពៅដឹងហេតុការណ៍ហើយ ក៏មានចិត្តលោភ ព្រោះឃើញរបស់ដែលយក្សឲ្យ មកសុទ្ធតែជារបស់ទិព្វ ក៏នឹកចង់បោកបញ្ឆោត ចៅមាណពដើម្បីយករបស់នោះ។

ពេលនោះនាយសំពៅក៏ធ្វើល្បិចនិយាយទៅកាន់មាណពថា ៖ " ចៅមាណពឯងកុំកាន់ទៅណារហេតរហូត ប្រគល់ទ្រព្យសម្បត្តិហ្នឹងមក ឲ្យយើងទុកឲ្យ ទើបមានសុវត្ថិភាព ចាំទៅដល់ស្រុកទេសវិញចាំចៅមាណពឯងយករបស់ហ្នឹងវិញចុះ! " ។

មាណពស្តាប់ទៅដូចទំនងដែរ ព្រោះក្នុងសំពៅមានមនុស្សច្រើន ខ្លាចគេលួចយក ក៏សុខចិត្តប្រគល់របស់នោះទៅនាយសំពៅទុកឲ្យ។ ដល់ពេលបានរបស់ពីចៅមាណពយកទៅទុកហើយ នាយសំពៅក៏ប្រើកលឧបាយ។ នាយសំពៅក៏ឲ្យគេតំរង់សំពៅទៅរកកោះមួយ ហើយចុះចតលើកោះនោះ។ អ្នកខ្លះនាំគ្នាមុជទឹកលេងខ្លះក៏ទៅបេះផ្លែឈើនៅលើកោះហូបកម្សាន្ត។ មាណពក៏ចុះដើរលេងនឹងគេ និងបេះផ្លែឈើនៅលើកោះនឹងគេដែរ។ ចំណែកឯម្ចាស់សំពៅបានរៀបចំផែនការជាស្រេច គាត់ក៏បានឲ្យកម្មករដើរប្រមូលគ្នាឡើងសំពៅជាសម្ងាត់។ គេក៏បានបើកសំពៅចោលមាណពឲ្យនៅកណ្តាលកោះតែម្នាក់ឯងទៅ។

នៅកណ្តាលកោះតែម្នាក់ឯងដូច្នេះ មាណពកើតទុក្ខព្រួយយ៉ាងខ្លាំងហើយក៏អង្គុយយំតែឯង ដោយមិន

ដីឯជាទៅណារួចព្រោះសុទ្ធតែទឹកនៅជុំវិញ។ ចៃដន្យពេលនោះ មានសត្វជ្រូកមួយខាំពាំកែវហោះកាត់សមុទ្រមក រួចចុះស៊ីផ្លែល្វាដែលដុះនៅលើកោះហ្នឹង។ នៅពេលដែលជ្រូកហោះមកហ្នឹង ថៅមាណពបានទៅលាក់ខ្លួនលើដើមល្វា។ កាលជ្រូកមកដល់ វាទុកកែវហោះនៅគល់ល្វាដែលមាណពហ្នឹងឡើងលាក់ខ្លួននោះ ហើយវាក៏ដើររើសផ្លែល្វាដែលជ្រុះលើដីស៊ី។ វាស៊ី វាសប្បាយ វារត់លេង វាឈ្ងុសដីលេង មាណពហ្នឹងឃើញដូច្នេះក៏ប្រើល្បិចបេះផ្លែល្វាទុំៗ ទម្លាក់ចុះទៅឲ្យជ្រូកស៊ីដើម្បីបញ្ឆោតវាក្នុងបំណងយកកែវហោះនោះ។ គាត់បេះទំលាក់ម្តងក្បែរគល់ល្វា ម្តងទៀតឆ្ងាយពីគល់ល្វាបន្តិច ទម្លាក់ក្រោយទៀតកាន់តែឆ្ងាយទៅៗ ចំណែកឯជ្រូកហ្នឹងចេះតែតាមស៊ីទៅៗដែរ។ មាណពក៏សម្រូតខ្លួនចុះមកយកកែវនោះហើយហោះទៅតាមសំពៅ។ មិនយូរប៉ុន្មានថៅមាណពក៏ហោះទៅតាមទាន់សំពៅ។ ម្ចាស់សំពៅឃើញដូចនេះ ក៏នឹកខ្លាចអំណាចរបស់ថៅមាណពហើយលែងហ៊ានបោកប្រាសគាត់ទៀត ហើយសុខចិត្តប្រគល់ខ្សែចង ដំបងវាយ និងថ្នាំធ្មិនឯងដំបងឲ្យទៅថៅមាណពវិញ។

ពេលសំពៅទៅដល់កំពង់ផែ ថៅមាណពក៏លាម្ចាស់សំពៅធ្វើដំណើរទៅផ្ទះរបស់ខ្លួន។ គាប់ចួនពេលដែលគាត់មកដល់ផ្ទះនោះ ចំពេលយប់ងងឹតទៀត។ ដូច្នេះ គាត់ក៏មិនទាន់យករបស់ទិព្វទាំងនេះទៅលើផ្ទះភ្លាមទេ គឺគាត់ជីកដីកប់ទុកក្រោមជណ្តើរ។ និយាយពីប្រពន្ធមាណពម្តង ពេលដែលមាណពចេញទៅរៀនវិជ្ជាសិល្បសាស្ត្រជាមួយគ្រូអាចារ្យ ប្រពន្ធគាត់ឥតស្មោះត្រង់នឹងគាត់ទេ បែរជាលួចមានសាហាយស្មន់ទៅវិញ។ សាហាយនោះមករួមដំណេកជាមួយនឹងប្រពន្ធមាណពរៀងរាល់យប់។ យប់ដែលមាណពត្រឡប់មកផ្ទះវិញសាហាយនោះក៏នៅលើផ្ទះផងដែរ។ មាណពស្រែកហៅប្រពន្ធគាត់ពីចំងាយឲ្យបើកទ្វារ។ សាហាយស្មន់នោះ

ពួហើយ ក៏ស្ទុះចុះតាមបង្អួចសំរូតតាមសសរមកលាក់ខ្លួននៅក្រោមផ្ទះៗ ពេលថៅមាណពនោះកប់របស់របររួចហើយក៏ឡើងទៅជួបប្រពន្ធៗ លុះឃើញប្ដីមកភ្លាម ប្រពន្ធមានមាយាចេះប្រណិប្រណាក់ប្រើល្បិចដូចជានឹកប្ដីខ្លាំងណាស់ នាំប្ដីទៅងូតទឹក ហើយដាំស្លឲ្យប្ដីហូប ធ្វើយ៉ាងណាអោយប្ដីលង់ចិត្ត រួចក៏ចូលដំណេកទៅៗ

ពេលចូលរួមដំណេកនឹងនាងជាប្រពន្ធ ប្រពន្ធក៏សួរមាណពនោះថា៖ " បងទៅយូរហើយ បងបានអីខ្លះ បងចេះអីខ្លះ? "

ពួប្រពន្ធសួរដូច្នោះ ថៅមាណពក៏នឹកដល់បណ្ដាំគ្រូដែលបានបង្រៀនពីសុកាសិតតម្លៃ៣០តម្លឹងដែលចេះចាំរត់មាត់ថា៖ " បើឃ្លានណាស់កុំស៊ី បើងងុយណាស់កុំដេក បើចូលដំណេកកុំនិយាយនឹងស្រី ។ "

ប៉ុន្តែ ដោយប្រពន្ធសួរដដឹកដដែលៗជាច្រើនលើកច្រើនសារ បុរសនោះមិនដាច់ចិត្តដោយគិតថា៖" ប្រពន្ធអញកំពុងតែល្អ ទោះប្ដីបែកយូរហើយក៏នៅតែចេះប្រណិប្រណាក់យកចិត្តស្មោះត្រង់នឹងប្ដីដដែល បើអញមិនប្រាប់ហាក់ដូចជាអញមិនស្មោះត្រង់នឹងប្រពន្ធ!"

គិតដូច្នោះហើយគាត់ក៏ដាច់ចិត្តរ៉ាយរាប់ប្រាប់ប្រពន្ធថា៖ " បងទៅរៀនចេះដឹងបានគ្រាន់បើដែរ ហើយពេលត្រលប់មកវិញក៏បានជួបនូវហេតុការណ៍មួយចំនួនៗ ដំបូងបងបានខ្សែចង ដំបង វាយ និងថ្នាំផ្សិនឯងពីយក្សៗ បន្ទាប់មកទៀតក៏យកបានកែវហោះពីជ្រូកហោះដេញតាមសំពៅ! "

ដល់ពួដូច្នោះ ប្រពន្ធសួរថា៖ " ចុះរបស់ទាំងនេះទុកនៅឯណា? "

ប្ដីប្រាប់ថា៖ " របស់ហ្នឹងបងមិនទាន់បានយកមកឡើងលើផ្ទះទេ បងកប់ទុកនៅក្រោមជណ្ដើរផ្ទះឯណោះ! "

ថែជនទ្យនាពេលនោះ អាសាហាយកំពុងនៅក្រោមផ្ទះនៅឡើយ។ លុះបានព្រួថៅមាណពនិយាយដូច្នោះ សាហាយនោះក៏ទៅគាស់យករបស់នៅក្រោមជណ្ដើរផ្ទះនោះទៅ។

ដល់ព្រឹកឡើង ថៅមាណពចុះមក ហើយទៅរកមើលសម្បត្តិទិព្វនោះ ក៏រកមិនឃើញ ហើយត្រូវប្រពន្ធគាត់ត្មេះតិះដៀលថាករគេទៀត។ មិនដឹងធ្វើយ៉ាងម៉េច មាណពនោះក៏សំរេចអូសជណ្ដើរនោះទៅប្ដឹង។ បុរសនោះចេះតែអូសជណ្ដើរទៅប្ដឹងពីកន្លែងមួយទៅកន្លែងមួយ តែគ្មានថៅក្រមណាអាចកាត់ក្ដីបានឡើយ។ អញ្ចឹងគាត់ចេះតែអូសជណ្ដើរទៅប្ដឹងរហូតទៅដល់ព្រះរាជា។

ពេលទៅដល់ព្រះអង្គមានតម្រិះថា៖ " មាណពនេះមិនមែនជាអ្នកល្ងង់ទេ ពីព្រោះមនុស្សហ៊ានយកជណ្ដើរមកដើរប្ដឹងអញ្ចប៉ុណ្ណឹងច្បាស់ជាមានអាថ៌កំបាំងអីសំខាន់ណាស់ហើយ ម៉្យាងប្រហែលជាគាត់ចង់ស្វែងរកជនដែលមានបញ្ញាក្នុងនគរដើម្បីដោះស្រាយបញ្ហារបស់គាត់។"

លុះទ្រង់ព្រះតម្រិះដូច្នេះហើយ ព្រះអង្គក៏ទទួលយករឿងក្ដីនេះមកដោះស្រាយ រួចបានប្រាប់ទៅមាណពថា៖ " ឲ្យថៅឯងទុកជណ្ដើរត្រង់នេះចុះ ចាំយើងជួយដោះស្រាយឲ្យ! "

មាណពព្រួដូច្នោះក៏ទុកជណ្ដើរតាមព្រះរាជបញ្ជារបស់ស្ដេច។ រយៈកាលយូរថ្ងៃបន្ដិចមក ស្ដេចក៏រៀបចំពិធីបុណ្យមួយយ៉ាងធំក្នុងរាជវាំង ហើយបង្គាប់ឲ្យអាមាត្រទៅតាមថៅមាណពមក។

ព្រះអង្គក៏បានប្រទានសម្លៀកបំពាក់ គ្រឿងអលង្ការ គ្រឿងលាប គ្រឿងក្រអូប ទៅឲ្យថៅមាណពហើយប្រាប់ថា៖ " ថៅឯងយករបស់ទាំងនេះទៅឲ្យប្រពន្ធថៅឯងស្លៀកតុបតែងខ្លួនទៅចូលរួមបុណ្យនឹងគេចុះ!

ឯថៅឯងនៅចាំផ្ទះទៅមិនបាច់មកទេ! "

ពេលបានគ្រឿងអលង្ការ សម្លៀកបំពាក់ គ្រឿងលាបគ្រឿងក្រអូបហើយ ថៅមាណពក៏ប្រញាប់ប្រញាល់ត្រឡប់ទៅផ្ទះវិញ។

ពេលទៅដល់គាត់ក៏ហុចរបស់ទាំងនេះទៅឲ្យប្រពន្ធខ្លួន រួចប្រាប់ថា៖ " ស្ដេចសព្វព្រះរាជហឫទ័យឲ្យនាងទៅលេងបុណ្យនឹងគេ។ ព្រះអង្គឲ្យយើងនៅចាំផ្ទះ ព្រោះយើងចេញចូលវាំងបានសប្បាយញឹកញាប់ហើយ នាងមិនដែលស្គាល់វាំងអញ្ចឹង នាងទៅចុះ! "

គ្រាន់តែលឺអញ្ចឹង នាងជាប្រពន្ធបានឱកាស ក៏ទៅបបួលសាហាយហើយយកសម្លៀកបំពាក់សម្រាប់បុរសនិងគ្រឿងក្រអូប គ្រឿងលាបទៅសាហាយ ហើយបណ្ដើរគ្នាទៅលេងបុណ្យ។ ឯស្ដេចវិញបានដាក់អាមាត្យឲ្យយាមកាមចាំលបមើលថាតើនរណាស្លៀកសម្លៀកបំពាក់ដែលស្ដេចប្រទានឲ្យ។ បើឃើញកាលណាឲ្យហៅចូលវាំងភ្លាម។ ដល់នាងនេះនាំសាហាយដើរទៅលេងបុណ្យដោយស្លៀកសម្លៀកបំពាក់ដែលស្ដេចប្រទានឲ្យប្លែកពីគេ អាមាត្យឃើញភ្លែតក៏ហៅអ្នកទាំងពីរនោះឲ្យចូលវាំង។ ពេលចូលទៅដល់វាំង ស្ដេចក៏ឲ្យគេទៅតាមហៅថៅមាណពនោះមក។

ថៅមាណពក៏ទូលព្រះរាជាថា៖ " នេះជាប្រពន្ធរបស់ទូលបង្គំ! "

ឯនាងជាប្រពន្ធក៏សារភាពថាបុរសដែលដើរលេងបុណ្យជាមួយនោះជាសាហាយរបស់ខ្លួន ។ ព្រះមហាក្សត្រក៏សួរដេញដោលពីរបស់ដែលបាត់នៅក្រោមជណ្ដើរផ្ទះថៅមាណព។ បុរសជាសាហាយក៏សារ

ភាពថាខ្លួនបានលួចយកទ្រព្យសម្បត្តិគឺផ្ទាំងថ្មនិងឯង ខ្សែចងជំបង់វាយ និងកែវហោះនោះមែនៗ បន្ទាប់ពីដឹងរឿងដើមចមអស់ហើយ ចៅមាណពក៏ថ្វាយ របស់ទិព្វទាំងនោះទៅស្ដេចផែនដីៗ ស្ដេចមិនយកទោសពៃរ៍ដែលនាងជាប្រពន្ធរបស់ចៅមាណពនិងសាហាយនោះទេ ដោយតាមសំណូមពររបស់ចៅមាណពដែលថាបើគេមិនព្រម ស្មោះស្ម័គ្រនឹងខ្ញុំទៅហើយ គេស្រឡាញ់អ្នកដ៏ទៃហើយ ឲ្យគេស្រឡាញ់គ្នាទៅចុះ កុំចងកម្មចងកម្មពារនឹងគេអី! ស្ដេចក៏ដឹងថាខុសច្បាប់ព្រះនគរដែរ ក្នុងការដោះលែងអត់ឱនទោស តែនេះជាសំណូមពររបស់ចៅមាណពៗ

ជាការសងគុណវិញ ស្ដេចក៏សួរចៅមាណពថា៖ " តើចៅឯងចង់បានអី?សម្បត្តិក្នុងវាំងយើងមានទាំងប៉ុន្មានយើងឲ្យឯងរើសបានតាមចិត្ត! "

ចំណែកឯចៅមាណពគាត់ទៅរកមើលសម្បត្តិក្នុងវាំង គាត់គ្មានឃើញអីគួរឲ្យចាប់អារម្មណ៍សោះ គាត់បែរទៅឃើញកាំបិតបន្ទោះនៅបាតឃ្លាំង គាត់ស្រឡាញ់កាំបិតហ្នឹង ហើយគាត់ក៏រើសយកតែម្ដងទៅៗ បន្ទាប់ពីបានកាំបិតបន្ទោះពីស្ដេចហើយ ចៅមាណពក៏ត្រឡប់ទៅផ្ទះរបស់គាត់វិញៗ

និយាយពីសេដ្ឋីដែលមានកូនក្រមុំម្នាក់រស់នៅក្នុងស្រុកមួយ មានការកិតភ័យយ៉ាងខ្លាំងព្រោះដល់វេនខ្លួនទៅយាមក្នុងវាំងៗ គាត់ដឹងថាសេដ្ឋីមុនៗដែលបានទៅយាមនៅក្នុងវាំងពីមុនៗ ជាបន្តបន្ទាប់សុទ្ធតែត្រូវបានយកទៅសម្លាប់ចោលទាំងអស់ៗ សេដ្ឋីនោះភ័យណាស់ គាត់ក៏ទៅរកចៅមាណពដើម្បីឲ្យជួយៗ

សេដ្ឋីថា៖ " អ្នកឯងអាចទៅយាមជំនួសយើងបានទេ បើអ្នកឯងយល់ព្រម ហើយបើព្រឹកឡើងអ្នកឯង

មកវិញ ដោយនៅរស់ យើងនឹងលើកកូនក្រមុំឲ្យនិងឲ្យសម្បត្តិ សេដ្ឋីទាំងអស់ទៅចៅឯង! "

ពេលឮដូច្នេះចៅមាណពគិតថា ៖ " ហេតុដូចម្ដេចបានជាស្ដេចយកទោសដល់សេដ្ឋីទាំងអស់ដែលបានទៅយាម ហើយដល់ព្រឹកឡើងគេយកទៅសម្លាប់ចោលអញ្ចឹង តើមានរឿងអីប្លែក? "

ដូច្នេះហើយចៅមាណពក៏នឹកដល់សុភាសិតដែលគាត់បានរៀនចេះថា៖ " ឃ្លានកុំស៊ី ងងុយកុំដេក ចូលដំណេក កុំនិយាយនឹងស្រី! អញ្ចឹងមានតែអញយកសុភាសិតនោះមកអនុវត្តទៀត! "

ពេលមាណពរៀបចេញដំណើរទៅយាមជំនួសលោក សេដ្ឋីជប់លៀង ឲ្យផឹកឲ្យស៊ី តែចៅមាណពមិនព្រមផឹកមិនព្រមស៊ីទេ ទោះនាងក្រមុំកូនសេដ្ឋីអង្វរករយ៉ាងណាក៏ដោយ។ បន្ទាប់មកចៅមាណពបានចេញដំណើរទៅយាម។

ចំណែកនៅកន្លែងយាមឯណោះវិញ ពួករាជអាមាត្យ ពួកមហាតលិក និងពួកសេដ្ឋីផ្សេងទៀតសួរមាណពថា៖ " ឯងជាកូនសេដ្ឋីមកយាមជំនួសឪពុកឬ? "

មាណពឆ្លើយថា៖ " បាទ ខ្ញុំមកយាមជំនួសឪពុក! "

ឮដូច្នោះ ពួកអាមាត្រថា៖ " អើមុនយាម ចូរឯងផឹក ស៊ីឲ្យ ឆ្អែតសិនទៅ! "

ពួកគេក៏រៀបចំបាយទឹកឲ្យផឹកឲ្យស៊ី តែចៅមាណពមិនផឹកមិនស៊ីទេ គិតតែពីទន្ទេញសុភាសិត " ឃ្លានកុំស៊ី ងងុយកុំដេក ចូលដំណេកកុំនិយាយនឹងស្រី។ "

លុះគេផឹកគេស៊ីឆ្អែតអស់គ្រប់គ្នាហើយ ថៅមាណពក៏បានដើរចេញឆ្ងាយពីគេ ហើយទៅអង្គុយយាមតែម្នាក់ឯង។ ចំណែកអ្នកផ្សេងទៀត ក្រោយពីបានបរិភោគបាយ ស្រា ទឹក ត្នោតជូរ ឆ្អែតស្កប់ស្កល់ហើយ ក៏ស្រវឹងលង់លក់អស់ទៅ សល់តែមាណពម្នាក់ឯង។

និយាយពីពួកស្រីរបាំវិញម្ដង។ គេបានយកពួកនាងមកពិសោធន៍ជាមួយថៅមាណព។ គេបានឲ្យពួកនាងៗទៅបែចង់រូបគាត់ តែថៅមាណពឥតរវល់ឡើយ គិតតែខិតខំទន្ទេញសុភាសិត បើឃ្លានណាស់កុំស៊ី ងងុយណាស់កុំដេក ចូលដំណេក កុំនិយាយនឹងស្រី ។ ពួកស្រីៗហ្នឹងបបួលដេក បបួលធ្វើអីក៏ឥតរវល់ដែរ ចេះតែទន្ទេញសុភាសិតនោះ។ កណ្ដាលអាធ្រាតស្ដេចយាងចេញមកសាកល្បង។ សេដ្ឋីទាំងប៉ុន្មានដែលទៅយាមជាមួយសុទ្ធតែដេកលក់អស់ ដោយសារឆ្អែតបាយ ពុលស្រា។ ស្ដេចចេញឃើញពួកសេដ្ឋីទាំងនោះដេកដូច្នោះ ក៏ចាប់ដាក់ទោសទាំងអស់ទៅ រួចស្ដេចក៏យាងបន្តទៅចំមាត់ទ្វារដែលមាណពយាម ។ មាណពឃើញមនុស្សដូច្នោះ គាត់មិនដឹងថាជាស្ដេចទេ ក៏ស្ទុះយកកាំបិតបន្ទោះទៅចាក់ត្រូវស្ដេចសុគតមួយរំពេច។ ព្រឹកឡើងថៅមាណពក៏ត្រឡប់មកផ្ទះវិញ។ ឯសេដ្ឋីនោះគិតថាថៅមាណពមុខតែស្លាប់ដោយសារស្ដេចយកទៅសម្លាប់ជាមិនខាន ហេតុដូច្នេះហើយក៏គិតរៀបចំធ្វើបុណ្យឲ្យថៅនោះឲ្យហើយ ។ ប៉ុន្តែលុះព្រឹកឡើង ស្រាប់តែឃើញថៅមាណពត្រឡប់មកផ្ទះវិញ សេដ្ឋីក៏សុខចិត្តរៀបចំការកូនឲ្យទៅថៅមាណពនោះធ្វើជាភរិយា ព្រមទាំងប្រគល់ទ្រព្យសម្បត្តិឲ្យតាមការសន្យា។

ចំណែកនៅក្នុងនគរឯណោះវិញ គេនាំគ្នាផ្អើលឈូរឆរដោយសារតែស្ដេចសុគត ហើយក៏នាំគ្នារៀបចំធ្វើពិធីបូជាសពស្ដេចយ៉ាងអ៊ូអរ។ ឯមាណពវិញបានប្រពន្ធ ទ្រព្យសម្បត្តិ និងក្លាយជាសេដ្ឋីទៀតផង ។ ធម្មតា

តាមប្រពៃណី បន្ទាប់ពីស្ដេចសុគតហើយ គេធ្វើបុណ្យធំណាស់ គេហៅថាធ្វើបុណ្យបុស្បុកផ្សងដើម្បីស្វែងរកអ្នកមានបុណ្យមកសោយរាជ្យបន្ត។ បុស្បុកនេះមាន ដំរី ព្រះទីនាំងរបស់ស្ដេច។ គេឲ្យដំរីនឹងដើរទៅរកអ្នកមានបុណ្យ។ ដល់ដំរីដើរៗទៅចំពោះមុខ ថៅមាណពក៏លុតជង្គង់។ ហើយអាមាត្រក៏នាំថៅមាណពនោះមករាជវាំង។ ពេលមកដល់ សេនាបតីទាំងអស់ឃើញដឹងថាថៅមាណពជាអ្នកមានមហិទ្ធិរិទ្ធិអាចសម្លាប់ស្ដេចបាន ហើយជាអ្នកចេះការពារព្រះនគរ មិនចេះស៊ីផឹក មិនប្រព្រឹត្តិនូវអំពើអសីលធម៌ហើយជាអ្នកមានបារមីខ្លាំងក្លាអាចសម្លាប់ស្ដេចបានទៀតផង អញ្ចឹងត្រូវតែឲ្យសោយរាជ្យ ដោយតាមការផ្សងរបស់បុស្បុកនឹងចុះ។

គិតដូច្នេះហើយ មន្ត្រីសេនាបតីក៏ស្រុះស្រួលគ្នាលើកថៅមាណពអភិសេកឲ្យឡើងសោយរាជ្យទៅ។ ចំណែកឯស្ដេចក៏មានបុត្រីមួយអង្គដែរ មន្ត្រីទាំងអស់ក៏បានរៀបអភិសេកបុត្រីអង្គនេះឲ្យទៅថៅមាណព។ មាណពនោះបានប្រពន្ធពីរ ប្រពន្ធមួយជាកូនសេដ្ឋី មួយទៀតជាបុត្រីស្ដេច។

# ៩- រឿងអាមាត្យកាត់ក្តី

## និទានដោយៈ ព្រះតេជគុណ សឹម សេត [៨]



៨ អាស្រមប្រជុំត្រៃលក្ខណញាណតាកែវ ឃុំរកាក្នុង ស្រុកដូនកែវ ខេត្តតាកែវ

នៅសម័យពុទ្ធកាល មានព្រះរាជាមួយអង្គសោយរាជ្យនៅនគរមួយ។ ព្រះអង្គបានប្រគល់ភារកិច្ចឲ្យអាមាត្យ៥នាក់ទទួលបន្ទុកជាអ្នកកាត់ក្ដីប្រចាំនគរ ។ ដោយព្រះរាជាអង្គនោះមិនសូវយកចិត្តទុកដាក់ចំពោះការងារកាត់ក្ដីនេះ ទើបអាមាត្យទាំង៥នាក់ធ្វើការកាត់ក្ដីតាមទំនើងចិត្ត ។ ពួកនេះកាត់ក្ដីដោយស៊ីសំណូកកេងប្រវ័ញ្ចយកទ្រព្យសម្បត្តិរបស់ប្រជាជន។ អ្នកមានកំហុសដែលបានសូកគេនឹងត្រូវកាត់ក្ដីឲ្យឈ្នះ ហើយអ្នកដែលគ្មានកំហុសមិនបានសូកគេនឹងត្រូវកាត់ក្ដីឲ្យចាញ់ទៅវិញ ។

កាលនោះមានព្រះពោធិសត្វមួយអង្គ លោកនិមន្តមកគង់ស្នាក់អាស្រ័យនៅក្នុងនគរនោះ។ ព្រះរាជានៃនគរនោះបានឃើញ ក៏និមន្តព្រះពោធិសត្វឲ្យមកប្រទានឱវាទ និងឆាន់នៅរាជសំណាក់ព្រះរាជា។

កាលណោះជួនជាកើតមានរឿងប្រជាជនទាស់ទែងគ្នា ពុំអាចដោះស្រាយបាន ព្រះពោធិសត្វក៏បានជួយកាត់ក្ដីឲ្យ។ ព្រះពោធិសត្វកាត់ក្ដីរបស់ប្រជាជនប្រកបដោយយុត្តិធម៌ត្រឹមត្រូវ ដោយបានជួយកាត់ក្ដីអ្នកត្រូវឲ្យបានឈ្នះ អ្នកខុសត្រូវចាញ់។ មិនមែនអ្នកដែលត្រូវចាញ់ឲ្យឈ្នះ អ្នកដែលត្រូវឈ្នះឲ្យចាញ់ឡើយ ដូចការកាត់ក្ដីរបស់អាមាត្យនោះទេ។ ដល់ពេលអញ្ចឹង អ្នកប្ដឹងនិងប្រជាជនទាំងឡាយមានជំនឿលើព្រះពោធិសត្វយ៉ាងច្រើនកុះករ។ ចំណែកឯអាមាត្យទាំង៥នាក់ដែលស៊ីសំណូកវិញ បានធ្លាក់ពីតំណែងលែងបានកាត់ក្ដី ព្រោះប្រជាជនលែងមានជំនឿលើពួកគាត់ទៀតឡើយ។

ឃើញដូច្នេះ អាមាត្យទាំង៥នាក់ក៏ច្រណែននឹងព្រះពោធិសត្វ គិតរកល្បិចដើម្បីកម្ចាត់ព្រះពោធិសត្វ។

អាមាត្យគិតថា៖" អញ្ចឹងពួកយើងត្រូវទៅញុះញង់ព្រះរាជាថា តាបសនោះមកចង់ដណ្ដើមរាជសម្បត្តិរបស់ព្រះអង្គ។ "

គិតរួច អាមាត្រនោះក៏ទៅទូលព្រះរាជាថា៖ "ព្រះពោធិសត្វបាននាំបក្សពួកមកច្រើនណាស់ ក្នុងបំណង ដណ្ដើមរាជ្យហើយ!"

ព្រះរាជាក៏ជឿតាមសម្ដីរបស់អាមាត្យ។ គាប់ចួនជាពេលនោះ ព្រះរាជាបានឃើញប្រជាជនជាច្រើន ដែលស្រឡាញ់ព្រះពោធិសត្វដើរតាមចោមរោមជុំវិញព្រះអង្គមែន ព្រោះព្រះពោធិសត្វបានជួយដោះស្រាយ រឿងក្ដីឲ្យប្រជាជនបានត្រឹមត្រូវយុត្តិធម៌ ជាពិសេសព្រះពោធិសត្វបានជួយសើរើរឿងក្ដី ដែលអាមាត្យបាន កាត់ដោយអយុត្តិធម៌កន្លងមក។

ពេលនោះព្រះរាជាទ្រង់គិតថា៖ " មែនហើយ! អាមាត្រហ្នឹងនិយាយត្រូវ! ព្រះពោធិសត្វនាំទ័ពមកយ៉ាង នេះ លោតែថ្ងៃក្រោយរឹបយកនគរអញអស់ទៅ អញអស់អំណាចហើយនឹងធ្លាក់ពីរាជបល្ល័ង្កមិនខាន!"

គិតដូច្នេះហើយ ព្រះអង្គក៏មានគំនិតចង់សម្លាប់ព្រះបរមពោធិសត្វ។ មុនដំបូង ព្រះរាជារៀបបាយរៀប ចង្ហាន់យ៉ាងត្រឹមត្រូវថ្វាយព្រះពោធិសត្វ។ តែក្រោយមក ព្រះអង្គរៀបចំអាសនៈលែងត្រឹមត្រូវអស់ហើយ សូម្បីតែឥរិយាបទក៏លែងគោរពដល់ព្រះពោធិសត្វទៀតដែរ។ ព្រះបរមពោធិសត្វគិតថា៖ " គេលែងមានសទ្ធា នឹងខ្លួនអញទៀតហើយ! "

លុះព្រះពោធិសត្វមកលើកក្រោយៗទៀត ព្រះរាជាទៅទទួលព្រះពោធិសត្វត្រឹមតែខ្លោងទ្វារប៉ុណ្ណោះ ហើយបន្ថយចង្ហាន់ក្នុងបំណងមិនចង់ឲ្យព្រះពោធិសត្វនិមន្តមកទៀត។ មកដល់ត្រឹមខ្លោងទ្វារព្រះរាជាគិតទៀត ថា៖ " យើងឯងខំបន្ថយចង្ហាន់ប៉ុណ្ណឹងហើយនៅតែមកទៀត! "

ក្នុងព្រះរាជហឫទ័យកាន់តែក្រហល់ក្រហាយឡើងៗ ព្រះរាជាគិតថាមានតែផ្លូវមួយគឺ**សម្លាប់**!

ក្នុងកាលណោះមានឆ្កែមួយនឹកគុណដល់បរមពោធិសត្វដែលធ្លាប់បានឲ្យបាយមួយដុំដល់ខ្លួន។ វាលបស្ដាប់ឮព្រះរាជានិងមហេសីនិយាយរឿងចង់សម្លាប់ព្រះពោធិសត្វបែបនេះ វាក៏សម្រេចចិត្តថាទៅស្ទាក់ផ្លូវព្រះពោធិសត្វដើម្បីប្រាប់ហេតុការណ៍។ ពេលព្រលឹមមកដល់ឆ្កែនោះនៅចាំស្ទាក់ផ្លូវក្បែរខ្លោងទ្វារ ចាំមើលព្រះបរមពោធិសត្វ ហើយឲ្យសញ្ញាប្រាប់ដល់ព្រះបរមពោធិសត្វ។ ចំណែកឯព្រះពោធិសត្វចេះស្ដាប់ភាសាសត្វក៏យល់ន័យរបស់ឆ្កែនោះ។ ពេលនោះគ្រាន់តែឆ្កែព្រូសឲ្យសញ្ញាភ្លាម ព្រះពោធិសត្វដឹងថាថ្ងៃហ្នឹងឲ្យតែមកប្រាកដជាស្លាប់មិនខាន។ ដូច្នេះព្រះពោធិសត្វមិននិមន្តមកទៀតទេ។ ព្រះអង្គក៏និមន្តត្រឡប់ទៅវិញ។ លុះបាត់ដំណឹងយូៗទៅ ថ្ងៃក្រោយមកអាមាត្យទាំង៥ដែលពូកែខាងស៊ីសំណូកក៏មានអំណាចឡើងវិញ។

ក្នុងពេលនោះ ពេលប្រជាជនមានរឿង ព្រះបរមពោធិសត្វក៏និមន្តត្រឡប់មកវិញដូចធម្មតាពុំមានខ្វាយខ្វល់អ្វីឡើយ។ ព្រះរាជាបានឃើញដូច្នេះ ព្រះអង្គក៏ប្ដូរព្រះហឫទ័យលែងចង់សម្លាប់ព្រះពោធិសត្វទៀតហើយ ព្រោះព្រះអង្គយល់ថាតាបសនេះមិនមែនចង់មកកេងប្រវ័ញ្ចទ្រព្យ ឬចង់ដណ្ដើមរាជ្យអញអ្វីទេ។ ពេលនោះព្រះរាជាទ្រង់នៅស្ងៀមលែងនឹកចង់សម្លាប់ព្រះបរមពោធិសត្វទៀតឡើយ។

# ១០- រឿងស្ត្រីពីរនាក់ដណ្ដើមកូនគ្នា

និទានដោយៈ លោក ជា ជឿន



"រឿងស្ត្រីពីរនាក់ដណ្ដើមកូនគ្នានេះ មានពាក់ព័ន្ធនឹងរឿងជាតកខាងព្រះពុទ្ធសាសនាផង ហើយក៏ជារឿងព្រេងដែរ ដូច្នេះខ្ញុំនិយាយតាមរឿងព្រេងវិញចុះ ! "

មានតំណាលមកថា ស្ត្រីពីរនាក់ជាមិត្តភក្តិនឹងគ្នា។ ស្ត្រីទាំងពីរនាក់ឆ្លងទន្លេជំណាលគ្នា ។ ក្រោយពេលឆ្លងទន្លេបានហើយ កូនស្ត្រីម្នាក់ក៏ស្លាប់ទៅ ឯកូនស្ត្រីម្នាក់ទៀតនៅរស់ធម្មតា ។ សម័យថ្ងៃក្រោយមក ម្ដាយដែលមានទារកស្លាប់នឹកចង់បានយកកូនរបស់មិត្តភក្តិ ។ នាងតែងតែមកលេងថ្នាក់ថ្នមបីបមបំពេលួងលោមកូននោះជារៀងរាល់ថ្ងៃ ។ កូននេះវាស្គាល់និងស្រលាញ់ស្ត្រីនេះជាងម្ដាយបង្កើតរបស់វាទៅទៀត។ ថ្ងៃមួយស្ត្រីដែលមានកូនស្លាប់នោះបានចោទប្រកាន់ថា កូននេះជាកូនរបស់ខ្លួន ។ ស្ត្រីជាម្ដាយបង្កើតឃើញគេចោទទាំងបំពានយកកូនរបស់ខ្លួនដូចនេះ ក៏កើតក្តីក្តៅក្រហាយយំខ្សឹកខ្សួល រួចបានទៅប្ដឹងដល់ចៅក្រមដើម្បីជួយកាត់ក្ដីយកកូនខ្លួនត្រឡប់មកវិញ ។

ចៅក្រមថ្នាក់ក្រោមបានសម្រេចកាត់ក្តីឲ្យនាងដែលបំពានចង់បានកូនរបស់គេ សន្មត់ថាជាម្ដាយបង្កើត ព្រោះលោកសំអាងទៅលើកូននោះស្រលាញ់ម្ដាយក្មេងក្លាយ ជាងម្ដាយបង្កើតរបស់វាដែលរវល់តែទៅរកស៊ីបាត់ៗ។ នាងជាម្ដាយបង្កើតមិនសុខចិត្តចំពោះការកាត់ក្តីនេះក៏បានបន្តការប្ដឹងផ្ដល់រហូតឡើងដល់ព្រះមហាក្សត្រ។ ក្រោយពីព្រះមហាក្សត្រទ្រង់ព្រះសណ្ដាប់របាយការណ៍កាត់ក្តីរបស់អង្គចៅក្រមដែលបានសម្រេចកាត់ក្តីឲ្យកូនទៅម្ដាយក្មេងក្លាយជាអ្នកឈ្នះ ដោយសំអាងលើការស្រលាញ់របស់កូនចំពោះម្ដាយក្មេងក្លាយជាងម្ដាយបង្កើត ព្រះមហាក្សត្រទ្រង់ជាក្សត្រប្រកបដោយទសពិធរាជធម៌ ព្រះអង្គមិនយកការកាត់ក្តីរបស់ចៅក្រមជាកត្តាសំខាន់ទេ គឺទ្រង់ត្រូវការសម្រេចសេចក្តីដោយថ្លឹងថ្លែងតាមព្រះរាជប្រាជ្ញាញាណរបស់ទ្រង់ ។

ព្រះអង្គក៏មានព្រះរាជតម្រិះថា៖ " ឲ្យយកកូននេះដាក់ចំកណ្ដាល ហើយឲ្យស្ត្រីទាំងពីរនាក់ដណ្ដើមគ្នា បើអ្នកណាដណ្ដើមឈ្នះ អ្នកនោះគឺជាម្ដាយបង្កើត! "

ព្រះមហាក្រត្យក៏ត្រាស់បង្គាប់ឲ្យមន្ត្រី សេនា អាមាត្យរៀបចំចាត់ចែងពិធីនេះឡើង ហើយព្រះអង្គជាអធិបតីគង់នៅចាំទតមើលដោយផ្ទាល់។

លុះយកកូនដាក់ចំកណ្ដាលហើយ ស្ត្រីទាំងពីរនាក់ក៏ចូលមកដណ្ដើមយកកូនតែរៀងៗខ្លួន។ ធម្មតាការដណ្ដើមគ្នាដើម្បីយកឈ្នះ គេត្រូវអូសទាញចាប់ជើងចាប់ដៃយកអស់ពីកម្លាំង ពុំគិតពីគ្រោះថ្នាក់ឬការឈឺចាប់របស់ក្មេងនោះទេ។ ស្ត្រីទាំងពីរនាក់ទាញក្មេងប្រៀបបីដូចជាទាញព្រ័តអញ្ចឹង ជាហេតុធ្វើឲ្យក្មេងមានការឈឺចាប់ហើយយំ។ លុះឃើញដូច្នេះម្ដាយបង្កើតក៏អាណិតកូន ព្រោះឃើញកូនយំស្រែកយ៉ាងខ្លាំង។ ដូចនេះស្ត្រីជាម្ដាយនោះក៏ពុំហ៊ានទាញដណ្ដើមកូនឲ្យខ្លាំងឡើយ ធ្វើឲ្យស្ត្រីម្នាក់ទៀតដណ្ដើមកូននោះបាន។ ពួកមន្ត្រីសេនាអាមាត្យឃើញលទ្ធផលបែបនេះក៏បានទះដៃអបអរសាទរ ដោយអាចរកឃើញម្ដាយបង្កើតដែលជាអ្នកឈ្នះ ។ ព្រះមហាក្សត្រក៏ពុំទាន់មានព្រះរាជតម្រិះអារកាត់សេចក្ដីភ្លាមៗដែរ ទ្រង់គង់នៅស្ងៀម។

បន្ទាប់ពីពួកមន្ត្រី សេនា អាមាត្យ ហ៊ោអបអរសាទរចប់ហើយ ទើបព្រះអង្គកោះហៅស្ត្រីទាំងពីរនាក់មកហើយបានកាត់សេចក្ដីថា៖ " កូននេះមិនមែនជាកូនរបស់អ្នកដែលទាញឈ្នះគេនោះទេ គឺជាកូនរបស់អ្នកដែលដណ្ដើមចាញ់គេ! "

ទ្រង់ក៏បានបកស្រាយបន្ថែមទៀតថា៖ " ហេតុបានជាយើងកាត់ក្ដីឲ្យអ្នកទាំងពីរដូចនេះ ក៏ព្រោះតែមានមូលហេតុសំខាន់គឺ បុគ្គលដែលធ្វើជាឪពុកម្ដាយគេតែងតែមានព្រហ្មវិហារធម៌បួនយ៉ាងគឺមេត្តា ករុណា មុទិតា

និងឧបេក្ខា ។ អ្នកដែលគ្មានព្រហ្មវិហារធម៌ទាំង៤នេះ អ្នកនោះមិនមែនជាម៉ែឪទេ។ អញ្ចឹងនាងដែលចាញ់គេ មកពីនាងអាណិតឃើញកូនយំ នាងមិនហ៊ានឱប មិនហ៊ានរឹត មិនហ៊ានទាញប្រចាប់សាច់កូនឲ្យខ្លាំង ដោយសារតែនាងមានធម៌ទាំងបួននៅក្នុងខ្លួន ទើបនាងសុខចិត្តចាញ់ដើម្បីកុំឲ្យកូនមានការឈឺចាប់ កុំឲ្យកូនកូនស្រែកយំខ្លាំងពេកទើបនាងប្រលែងកូនឲ្យទៅគេចុះ។ ចំណែកឯនាងដែលដណ្ដើមចង់ឈ្នះនោះគឺជាស្ដ្រីដែលមានចិត្តកាឡកិណីហើយចង់បានប្រវញ្ចយកកូនគេតែប៉ុណ្ណោះ។ នាងមិនបានគិតពីកុមារនោះ ទោះបីជាកូនត្រូវបែកខ្លួនជាពីរស្លាប់ ក៏នាងមិនព្រមចុះចាញ់ដែរ។ នាងគិតតែអូសទាញដណ្ដើមយកឲ្យទាល់តែបានឈ្នះ! "

ក្រោយពីបានស្ដាប់ការបកស្រាយប្រកបដោយព្រះរាជបញ្ញាញាណរបស់ព្រះមហាក្សត្ររួចមក បណ្ដាអស់លោកមន្ត្រី សេនា បតីក៏អបអរសាទរទូងស្គរសរសើរអំពីព្រះរាជតម្រិះកាត់សេចក្ដីរបស់ព្រះអង្គ ៕

# ១១- រឿងក្រពើ និងអ្នកបរទេះ

## និទានដោយៈ លោក ម៉ែន វណ្ណៈ [៩]



៩ ទីលំនៅនៅភូមិឪភាសាំង ឃុំកណ្ដឹង ស្រុកបាទី ខេត្តតាកែវ

ថ្ងៃមួយ មានតាម្នាក់បររទេះកាត់តាមដងព្រៃមួយ ហើយក៏បានឃើញបឹងមួយគោកទឹកអស់រលីង។ គាត់ឃើញក្រពើមួយមានស្បែកស្ងួតស្រការរក្រៀមស្វិតអស់កំពុងតែវាខ្វាសៗនៅទីនោះ។

ពេលឃើញតាមកដូច្នេះ ក្រពើក៏និយាយទៅកាន់តាថា៖ " តាអើយអាណិតជួយយកអាសាខ្ញុំផង ជួយយកខ្ញុំទៅដាក់នៅកន្លែងដែលមានទឹកជ្រៅ ព្រោះខ្ញុំជិតស្លាប់ហើយ។"

ដោយសារក្រពើរអង្វរដូច្នោះ តានោះក៏យកក្រពើទៅចងរឹតជាប់នឹងទូករទេះ ហើយក៏បរចេញទៅ។ ទៅដល់កន្លែងមានទឹកសមគួរហើយ តានោះក៏ដាក់ក្រពើចុះ។

ចំណែកឯក្រពើនៅពេលបានដល់កន្លែងដែលមានទឹកជ្រៅហើយ វាក៏សប្បាយរីករាយរួចក៏បាននិយាយទៅកាន់តានោះថា៖ "យើសតាឯងទៅណាឥតរួចទេ! ព្រោះអំបាញ់មិញតាឯងចងរឹតអញខ្លាំងណាស់! ឥឡូវបើតាឯងមិនឲ្យគោអញស៊ីទេ អញនឹងស៊ីតាឯង តាឯងមិនរួចខ្លួនទេ ដូច្នេះត្រូវតែឲ្យគោតាឯងមកអញស៊ី! "

ក្រពើឃ្លានខ្លាំងព្រោះវាកំពុងអត់ចំណី។ តានោះភ័យណាស់ គាត់ក៏និយាយថា៖ "កុំទាន់អាលស៊ីអី ចាំខ្ញុំទៅរកអ្នកកាត់ក្ដីសិន ព្រោះខ្ញុំបានជួយឯងបែរជាឯងចង់ស៊ីខ្ញុំវិញ ខ្ញុំមិនសុខចិត្តទេ។ "

រួចហើយតាក៏ដើរទៅរកអ្នកកាត់ក្ដី។ ទៅតាមផ្លូវក៏បានជួបនឹងសុភាទន្សាយ។

សុភាទន្សាយសួរថា៖" តាអញ្ជើញទៅណា មុខស្រងូតស្រងាត់ម៉្លេះហើយយំផងអីផងដូច្នេះ? "

តាឆ្លើយទៅកាន់អ្នកកាត់ក្ដីថា៖ "ខ្ញុំខំដឹកក្រពើពីបឹងអត់ទឹកមករហូតដល់កន្លែងមានទឹក ស្រាប់តែវាបែរជាចង់ស៊ីគោខ្ញុំ មិនតែប៉ុណ្ណោះវាថែមទាំងចង់ស៊ីខ្ញុំទៀត។ "

ឮដូច្នេះ ទន្សាយតបថា៖ " មិនអីទេអញ្ចឹង! តាឯងទៅមុនចុះ ខ្ញុំទៅតាមក្រោយឥឡូវនេះហើយ។ "

តានោះក៏បានធ្វើដំណើរត្រឡប់មកវិញ ចំណែកឯទន្សាយក៏មកតាមក្រោយ។

ពេលមកដល់ ទន្សាយក៏សួរតាថា៖ " ម៉េចតា! មានរឿងយ៉ាងដូចម្ដេចអំបាញ់មិញ? "

តាឆ្លើយថា៖ " សត្វក្រពើនេះ! ខ្ញុំខំយកអាសារវាពីបឹងមក ព្រោះបឹងនោះអត់មានទឹក ហើយឃើញក្រពើប្រេះស្រកាអស់ហើយ ដូច្នោះខ្ញុំក៏នាំវាមកដាក់បឹងនេះ ឥឡូវវារមិលគុណខ្ញុំ វាចង់ស៊ីគោខ្ញុំ ហើយថែមទាំងចង់ស៊ីខ្ញុំទៀត។ "

ទន្សាយសួរ៖ "តើកាលតាឯងដឹកក្រពើហ្នឹងរបៀបណា? "

តាឆ្លើយថា៖ "ខ្ញុំចងវានឹងទូករទេះមក។ "

ពេលឮដូច្នេះ ក្រពើតបថា៖ "អ្ហោ! បើរឹតខ្ញុំល្មមៗ ខ្ញុំអត់ឈឺទេ ប៉ុន្ដែរឹតខ្ញុំខ្លាំងពេកបានខ្ញុំឈឺ។ "

តាក៏ថា៖ "ឃើ! ខ្ញុំចង់ជួយឯង ឥឡូវម៉េចឯងមកធ្វើបាបខ្ញុំទៅវិញ។ "

ក្រពើថា៖ "តាឯងចងខ្ញុំខ្លាំងណាស់"។ ពេលនោះទន្សាយក៏ពោលថា។ "

អញ្ចឹងពេលតាឯងចងមករបៀបម៉េច មើលតាធ្វើម្ដងទៀតមើល? "

តាក៏យកក្រពើនោះមកចងនៅលើទូករទេះជាថ្មីម្ដងទៀត។ ពេលចងរួចរាល់ហើយក្រពើថា៖ " មិនមែនចងប៉ុណ្ណឹងទេ បើចងប៉ុណ្ណឹងខ្ញុំអត់ឈឺទេ។ "

តាក៏ចងម្ដងទៀតតែតារឹតល្មមៗ។

ក្រពើថា៖ " អត់ទេអត់ទាន់យកទេប៉ុណ្ណឹង រឹតថែមទៀតព្រោះពេលយកមករឹតខ្លាំងណាស់ មិនមែនប៉ុណ្ណឹងទេ។ "

រួចតាក៏បានយកកូនកំព្រា[១០]នោះរឹតឲ្យខ្លាំង ឲ្យតឹង។

ក្រពើថា៖ "អើប៉ុណ្ណឹង! "

ដល់វាដកដង្ហើមលែងរួចវាថា៖ " ហ្នឹងប៉ុណ្ណឹង។ "

ទន្សាយថា៖ " យីនែតា! ពូថៅនៅលើរទេះទុកធ្វើអីទៀត ម៉េចមិនដាក់ទៅ ហើយតានោះក៏យកពូថៅកាប់អារមិលគុណាហ្នឹង មួយពូថៅស្លាប់ទៅហោង" ៕

១០ គឺជាវិធីចងម្យ៉ាងរបស់ខ្មែរដើម្បីធ្វើឲ្យយើងរឹតកាន់តែតឹងមាំល្អ (ប្រសាសន៍របស់លោកអ៊ុំ មៀច ប៉ុណ្ណ)

# បញ្ជីឈ្មោះប្រជាជនដែលបានផ្ដល់បទសម្ភាសន៍

១. លោកតា ឆាយ កង ភេទប្រុស អាយុ៨២ឆ្នាំ នៅភូមិអង្គតាចន្ទ័ ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ

២. លោក ជា ជឿន ភេទប្រុស អាយុ៥៣ឆ្នាំ នៅភូមិថ្មី ឃុំរកាគយ ស្រុកកងមាស ខេត្តកំពង់ចាម

៣. លោកយាយ ហួន ភេទស្រី អាយុ៧២ឆ្នាំ នៅភូមិឃ្លាំងប្រាំ ឃុំវាំងចាស់ ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ

៤. លោក ម៉ែន វណ្ណៈ ភេទប្រុស អាយុ៥២ឆ្នាំ នៅភូមិឪភាសាំង ឃុំកណ្ដឹង ស្រុកបាទី ខេត្តតាកែវ

៥. ព្រះតេជគុណ សឹម សេត ភេទប្រុស អាយុ២៣ឆ្នាំ ជាព្រះសង្ឃនៅអាស្រមប្រជុំព្រះត្រៃលក្ខណ៍ញាណ តាកែវ ឃុំរការក្នុង ស្រុកដូនកែវ ខេត្តតាកែវ

៦. លោកអាចារ្យ អន ភេទប្រុស អាយុ៦០ឆ្នាំ នៅភូមិចិនដាំម្លូ ឃុំវាំងចាស់ ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ

៧. លោកអ៊ុំ ស៊ឹម ផូ ភេទប្រុស អាយុ៥៧ឆ្នាំ នៅភូមិហនុមាណ ឃុំក្រាំងធ្នុង ស្រុកបាទី ខេត្តតាកែវ